# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី១ លេខ២ ត្រីមាសទី២ ឆ្នាំ២០២៤





រៀបរៀងដោយៈ
អគ្គលេខាធិការដ្ឋាន នៃសមាគមឧកញ៉ាកម្ពុជា

# មាតិកា


- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចាត់តាំង អ្នកឧកញ៉ា ផៃ ហុកឈួន ដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការវិនិយោគនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា.......................................................១
- លោកអ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំសមាជិកចូលរួមគោរពវិញ្ញាណក្ខន្ធសព អ្នកឧកញ៉ាមហាឧបាសក គឹម ចំរើន ដែលជាឪពុកក្មេក អ្នកឧកញ៉ា លាង ម៉េង............៣
- សមាគមឧកញ៉ាកម្ពុជារៀបចំសន្និបាតលើកទី១បូកសរុបលទ្ធផលការងារឆ្នាំ២០២៣និងទិសដៅផែនការឆ្នាំ២០២៤ព្រមទាំងពិធីពិសាអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជា.....................................................................................៤
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាអញ្ជើញជាអធិបតីនៃពិធីបើកសន្និបាតលើកទី១បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤.................................................................៤
- ពិធីបិទ និងបូកសរុបលទ្ធផលសន្និបាតក្រោមអធិបតីភាព ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា.....................៧
- សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនប្រធានព្រឹទ្ធសភានិងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជាអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីពិសាអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជា.................................................................១១
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ និងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីពិព័រណ៌រថយន្តលើកទី១ នៅអគារ ដឺ ព្រេមៀ សេនធ័រ សែនសុខ....................................១៤
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ក្នុងបេសកកម្មនៅប្រទេសជប៉ុនចាប់ថ្ងៃទី៦-១០ ខែឧសភា ឆ្នាំ២០២៤...........................១៦
- ជំនួបពិភាក្សាការងាររវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ( AJC )................................១៦
- ជំនួបពិភាក្សាការងាររវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយសម្ព័ន្ធសភាមិត្តភាពកម្ពុជា-ជប៉ុន...............................១៧
- សិក្ខាសាលាស្តីពីការវិនិយោគនៅកម្ពុជាដើម្បីផ្សព្វផ្សាយអំពីសក្តានុពលនិងកាលានុវត្តភាពវិនិយោគនៅកម្ពុជាទៅកាន់សហគ្រាសរបស់ជប៉ុន.......................................................................................................១៨
- ជំនួបពិភាក្សាការងាររវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាមួយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន ( JETRO ) និងជំនួបផ្លូវផ្លងធុរកិច្ចកម្ពុជា-ជប៉ុន.......................................................................................................១៩
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមពិធីប្រកាសបើកឱ្យដំណើរការជាផ្លូវការសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គី....................................................................២១
- កិច្ចប្រជុំគ.ព.វ.គលើកទី៥ដើម្បីពិភាក្សាសម្រេចលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការស្នើសុំនិងវាយតម្លៃក្នុងការផ្តល់គោរមងារឧកញ៉ា និងការបញ្ចប់គោរមងារឧកញ៉ា.............................................................២៣
- លោកអ្នកឧកញ៉ា លាង យុន តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមគោរពវិញ្ញាណក្ខន្ធ ឧកញ៉ា គី ទីតា សមាជិកនៃសមាគមឧកញ៉ាកម្ពុជា...........................................................២៤

- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៤ អាណត្តិទី១.........................................២៥
- អ្នកឧកញ៉ា សៀ ឫទ្ធី ដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់ធុរកិច្ច ( Business Lunch ) រវាងថ្នាក់ដឹកនាំក្រុមហ៊ុន សហគ្រាស និងធុរជននៃប្រទេសកម្ពុជា និងតួកគី.......................................................២៨
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ អមដំណើរដោយថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ ៣ឆ្នាំដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសិកា នង តាំងអ៊ីម....................២៩
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជាទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោក Makoto Matsukawa ប្រធានក្រុមហ៊ុន MK Co., Lt.........................................................................................៣០
- លោកអ្នកឧកញ៉ា លាង យុន ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស...........................................................................៣១
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ រួមជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការកំពង់ផែពហុបំណងកំពត.........................................................................................៣២
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មនៅសហភាពអឺរ៉ុប.......................................................៣៤
- លោក យឿម ប៉ូរ៉ាន អគ្គលេខាធិការរង តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាចូលរួមប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិង ផ្សព្វផ្សាយទេសចរណ៍កម្ពុជា ..............................................................៣៧
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ទទួលជួបនិងពិភាក្សាការងារជាមួយលោកអគ្គលេខាធិការសមាគមជប៉ុន-កម្ពុជា.................៣៨
- អ្នកឧកញ៉ា ហ៊ុន ឡាក់ ជួបពិភាក្សាការងារជាមួយលោកស្រី Marisa Haruta ប្រធានតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន ( JETRO ) ប្រចាំកម្ពុជា.........................................................................................................៣៩
- ពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា .........................................................................៤០
- លោកអ្នកឧកញ៉ា ហុង ស៊្វន ស៊ីគង់ទ្រីវ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធ ឧបាសិកា តាំង ប៉ជូរ.......................................................................................................................................៤៥

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចាត់តាំង អ្នកឧកញ៉ា ផៃ ហុកឈួន ដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការវិនិយោគនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នាព្រឹកថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ នាទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមទាំងថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាលនិងសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ៤០រូប បានចូលរួម សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីវិនិយោគ និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគក្រោមអធិបតីភាពឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួង/ស្ថាប័នរដ្ឋ ថ្នាក់រាជធានី-ខេត្ត និងធុរជន និងវិនិយោគិននៃវិស័យឯកជនជាច្រើន។

សិក្ខាសាលានេះ មានគោលបំណងចែករំលែកព័ត៌មាន និងបទពិសោធន៍ ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការវិនិយោគ សម្រាប់ជាមូលដ្ឋានជូនដល់សិក្ខាកាមឱ្យយល់កាន់តែច្បាស់ និងស៊ីជម្រៅអំពីច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។


















ថ្លែងក្នុងសិក្ខាសាលានេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានជម្រាបជូនអង្គសិក្ខាសាលាអំពីលទ្ធផលការងារដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រេចបានដោយលើកឡើងពីគម្រោងវិនិយោគដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តមានការកើនឡើងគួរកត់សម្គាល់ ក្នុងនោះឆ្នាំ២០២២ មានចំនួន ១៨៦គម្រោង ស្មើនឹងទឹកប្រាក់ចំនួន ៤ពាន់លានដុល្លារអាម៉េរិក ខណៈឆ្នាំ២០២៣ មានចំនួន ២៦៨គម្រោង ស្មើនឹងទឹកប្រាក់ចំនួន ៤.៩ពាន់លានដុល្លារអាម៉េរិក ដែលមានការកើនឡើង៤៤% លើចំនួនគម្រោង និង២២% លើចំនួនថវិកា។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏មានប្រសាសន៍ចែករំលែកផងដែរអំពីកត្តាទាក់ទាញវិនិយោគិនបរទេសឱ្យមកបោះទុនវិនិយោគនៅកម្ពុជាដែលរួមមាន (១) សន្តិភាព និងស្ថិរភាពនយោបាយ (២) ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (៣) ច្បាប់ស្តីពីវិនិយោគដែលមានការលើកទឹកចិត្ត និងបើកចំហទូលំទូលាយ (៤) រាជរដ្ឋាភិបាលមានការគាំទ្រ និងជួយសម្របសម្រួលដល់វិស័យឯកជន (៥) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ មានការអភិវឌ្ឍ និងការតភ្ជាប់កាន់តែល្អប្រសើរ (៦) ប្រជាជនវ័យក្មេងប្រកបដោយថាមពល (៧) ទីតាំងភូមិសាស្ត្រអំណោយផលស្ថិតនៅចំកណ្តាលនៃមហាអនុតំបន់ទន្លេមេគង្គ មានប្រជាជនចំនួន ២៥០លាននាក់ តំបន់អាស៊ាន មានប្រជាជន ៦៧១លាននាក់, និងក្នុងក្របខណ្ឌ RCEP មានប្រជាជន ២.៣ពាន់លាននាក់ ព្រមទាំងកត្តាបន្ទាប់បន្សំផ្សេងៗទៀត។

ជាកិច្ចបន្តវាគ្មិនមកពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗរួមមាន(១)ការជំរុញវិនិយោគ និងកិច្ចសម្រួលវិនិយោគ (២) ច្បាប់ស្តីពីវិនិយោគ និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគ និង (៣) នីតិវិធីចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

បន្ទាប់ពីបង្ហាញរួចមកអង្គសិក្ខាសាលាក៏បើកឱកាសជូនអ្នកចូលរួមលើកជាសំណូមពរនិងចោទសួរជាសំណួរពាក់ព័ន្ធនឹងច្បាប់ស្តីពីវិនិយោគ និងលិខិតបទដ្ឋានគតិយុត្តនានាខាងលើ ដើម្បីទទួលបានព័ត៌មានបន្ថែម ក៏ដូចជាបំបាត់រាល់ចម្ងល់នានាផងដែរ។

## លោកអ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំសមាជិកចូលរួមគោរពវិញ្ញាណក្ខន្ធសពអ្នកឧកញ៉ាមហាឧបាសក គីម ចំរើន ដែលជាឪពុកក្មេក អ្នកឧកញ៉ា លាង ម៉េង

នារសៀលថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី ហួរ តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជារួមជាមួយថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាជាច្រើនរូបទៀត បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ អ្នកឧកញ៉ាមហាឧបាសក គីម ចំរើន (លឹម តេកអៀក) ដែលត្រូវជាឪពុកបង្កើតរបស់លោកជំទាវ គីម ចាន់ណា និងឧកញ៉ា លឹម វុទ្ធី ព្រមទាំងជាឪពុកក្មេករបស់អ្នកឧកញ៉ា លាង ម៉េង ដែលបានទទួលមរណភាពកាលពីថ្ងៃពុធ ៩កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ១០:០៥ នាទីព្រឹកក្នុងជន្មាយុ ៨៣ឆ្នាំដោយជរាពាធ។

ក្នុងវេលាប្រកបដោយទុក្ខព្រួយដ៏សោកសង្រេងជាទីបំផុតនេះ លោកអ្នកឧកញ៉ា លី ហួរ បានចូលរួមរំលែកមរណទុក្ខដ៏ក្រៀមក្រំបំផុតជាមួយ អ្នកឧកញ៉ា ឧកញ៉ា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់អ្នកមានគុណមួយរូបជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅពោរពេញដោយព្រហ្មវិហារធម៌និងបានលះបង់បូជាកម្លាំងកាយកម្លាំងចិត្តគ្រប់សព្វបែបយ៉ាងក្នុងការបីបាច់ថែរក្សា បុត្រា បុត្រី ចៅប្រុស ចៅស្រី ឱ្យក្លាយជាពលរដ្ឋដ៏ល្អសម្រាប់សង្គមជាតិ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ អ្នកឧកញ៉ាមហាឧបាសក គីម ចំរើន សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។









## សមាគមឧកញ៉ាកម្ពុជារៀបចំសន្និបាតលើកទី១បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅផែនការឆ្នាំ២០២៤ ព្រមទាំងពិធីពិសាអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជា

អនុលោមតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សមាគមឧកញ៉ាកម្ពុជា បានរៀបចំនូវសន្និបាតលើកទី១ដើម្បីបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅផែនការឆ្នាំ២០២៤ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ នាសណ្ឋាគារ ហ្គាឌិន ស៊ីធី ព្រមទាំងពិធីពិសាអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជាក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា។

### លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាអញ្ជើញជាអធិបតីនៃពិធីបើកសន្និបាត លើកទី១បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤



នារសៀលថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ នៅសណ្ឋាគារហ្គាឌិនស៊ីធីសមាគមឧកញ៉ាកម្ពុជាបានរៀបចំពិធីបើកសន្និបាតលើកទី១បូកសរុបលទ្ធផលការងារ ឆ្នាំ២០២៣ និងលើកទិសដៅការងារ ឆ្នាំ២០២៤ ដោយមានវត្តមានលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ២០០រូប។

ជាកិច្ចចាប់ផ្តើម លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានថ្លែងមតិស្វាគមន៍និងបានជម្រាបជូនអង្គសន្និបាតពីសាវតាសង្ខេបនៃការបង្កើតសមាគមឧកញ៉ាកម្ពុជា នេះឡើងព្រមទាំងចក្ខុវិស័យ បេសកកម្មសំខាន់ៗនិងតួនាទីផងដែរជាពិសេសសមាគមឧកញ៉ាកម្ពុជាគឺជាស្ថាប័នតែមួយគត់ដែលតំណាងឱ្យគោរមវន្តទាំងអស់នៅកម្ពុជា និងជាដៃគូរាជរដ្ឋាភិបាលក្នុងសកម្មភាពជំរុញសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ ព្រមទាំងសកម្មភាពមនុស្សធម៌ និងសាមគ្គីភាពក្នុងមហាគ្រួសារឧកញ៉ាកម្ពុជា។ ទន្ទឹមនឹងនេះអ្នកឧកញ៉ាបានសង្កត់ធ្ងន់ថាយោងតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សមាគមបានកំណត់ថាការរៀបចំធ្វើសន្និបាតគឺត្រូវធ្វើជារៀងរាល់ឆ្នាំនៅក្នុងខែធ្នូនៃឆ្នាំនីមួយៗដើម្បីរាយការណ៍ពីសកម្មភាពសមាគមជូនសមាជិកទាំងអស់ស្តីពីលទ្ធផលសកម្មភាពឆ្នាំចាស់និងទិសដៅផែនការសកម្មភាពឆ្នាំថ្មីរបស់សមាគមឧកញ៉ាកម្ពុជា។

ដោយឡែកក្នុងឆ្នាំ២០២៣ថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាលបានសម្រេចពន្យារពេលរហូតដល់ខែមេសានេះ ពីព្រោះថានេះជាឆ្នាំដំបូងដែលសមាគមត្រូវរៀបចំសន្និបាតដូច្នេះការរកពេលវេលាសមស្របគឺជារឿងចាំបាច់។

របៀបវារៈបន្តជាបទបង្ហាញអំពីសមិទ្ធផលការងាររបស់គណៈកម្មការជំនាញទាំង៤នៅក្នុងឆ្នាំ២០២៣កន្លងមកដែលមានជាបន្តបន្ទាប់ដូចជា៖

១. បទបង្ហាញរបស់ អ្នកឧកញ៉ា ផៃ ហុកឈួន ប្រធានគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ អំពីការបំពេញការងារទូទៅរួមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុទាំងចំណូលចំណាយនិងសមតុល្យចុងគ្រាក្នុងឆ្នាំ២០២២និងឆ្នាំ២០២៣ដែលរបាយការណ៍ទាំងនេះត្រូវបានធ្វើសវនកម្មរួចរាល់ដោយសវនករឯករាជ្យ ។





២. បទបង្ហាញរបស់ អ្នកឧកញ៉ា លាង ម៉េង ប្រធានគណៈកម្មការកិច្ចការច្បាប់អំពីសមិទ្ធផលការងារលើការរៀបចំឯកសារគតិយុត្តនានាដើម្បីប្រើប្រាស់នៅក្នុងសមាគមនាឆ្នាំកន្លងមកក៏ដូចជាការបន្តចូលរួមក្នុងនាមជាដៃគូរាជរដ្ឋាភិបាលលើការពិនិត្យ វាយតម្លៃ លើកសំណើ និងបញ្ចប់គោរមងារឧកញ៉ា ព្រមទាំងការគាំពារផ្នែកច្បាប់ដើម្បីជាគុណប្រយោជន៍របស់គោរមវន្តនិងចំពោះសមាគមផងដែរ ។





៣. បទបង្ហាញរបស់ អ្នកឧកញ៉ា សៀ ឫទ្ធី ប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ ដោយរួមមានការងារទំនាក់ទំនង និងពាណិជ្ជកម្មអន្តរជាតិ ដោយអនុវត្តភាពនូវភាពជាដៃគូជាមួយរាជរដ្ឋាភិបាលជាពិសេសក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីឈានទៅរៀបចំវេទិកាធុរកិច្ចឆ្នាំ២០២៤ក៏ដូចជាបន្តកិច្ចសហការជាមួយបណ្តាស្ថាប័នជាដៃគូជាតិនិងអន្តរជាតិតាមរយៈការបញ្ជូនសមាសភាពពីសមាគមចូលរួមជាសមាជិកនៃគណៈកម្មការឬក្រុមប្រឹក្សានានា ព្រមទាំងការចាប់ដៃគូផ្គូផ្គងធុរកិច្ចជាមួយវិនិយោគិនបរទេសជាដើម ។





៤. បទបង្ហាញរបស់ លោកអ្នកឧកញ៉ា លី ហួរ ប្រធានគណៈកម្មការសមាជិកភាព វិន័យ និងក្រមសីលធម៌ ដោយបានផ្តោតជាសំខាន់លើការធ្វើបច្ចុប្បន្នកម្មនៃចំនួនសមាជិកដែលបានកើនដល់៣៦៥រូបគិតត្រឹមខែមេសាឆ្នាំ២០២៤និងបន្តគៀរគរបន្ថែមទៀតដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីការពារគុណតម្លៃនិងឧត្តមភាពគោរមវន្ត ជាពិសេសបន្តធ្វើសកម្មភាពសប្បុរសធម៌ និងកិច្ចការសង្គមដើម្បីជាឧត្តមប្រយោជន៍ដល់សង្គមជាតិ





៥. បទបង្ហាញរបស់ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការនៃសមាគមឧកញ៉ាកម្ពុជាលើចក្ខុវិស័យ និងបេសកកម្មរបស់សមាគមរួមជាមួយរចនាសម្ព័ន្ធដឹកនាំនិងកិច្ចការទូទៅរបស់អគ្គលេខាធិការដ្ឋានដែលជាសេនាធិការទទួលបន្ទុកបំពេញការងារប្រចាំថ្ងៃតាមការសម្រេចរបស់ថ្នាក់ដឹកនាំនិងតាមការចាំបាច់របស់គណៈកម្មការជំនាញទាំង៤ជាពិសេសបន្តអភិវឌ្ឍនិងបោះពុម្ព សៀវភៅឧកញ៉ា សៀវភៅសកម្មភាព ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស និងឯកសារនានា។





បន្ទាប់មកទៀតអង្គសន្និបាតទាំងមូលបានឈានចូលដល់របៀបវារៈសំណួរចម្លើយដែលបានផ្តល់ឱកាសដល់សមាជិកលើកឡើងនូវសំណួរក៏ដូចជាសំណូមពរនានាដើម្បីចូលរួមផ្តល់នូវទស្សនាទានល្អៗក្នុងការចូលរួមចំណែកអភិវឌ្ឍសមាគមឱ្យកាន់តែល្អប្រសើរ និងបំពេញការងារប្រកបដោយផ្លែផ្កាជាវិជ្ជមាន។ របៀបវារៈនេះបានដំណើរការទៅដោយផុសផុល និងមានការចោទសួរ ព្រមទាំងបកស្រាយយ៉ាងលម្អិតដោយប្រធានគណៈកម្មជំនាញនីមួយៗ។

## ពិធីបិទ និងបូកសរុបលទ្ធផលសន្និបាតក្រោមអធិបតីភាពឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តម វង្សី វិស្សុត** ឧបនាយករដ្ឋមន្ត្រីប្រចាំការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតលើកទី១ ឆ្នាំ២០២៣ និងទិសដៅផែនការឆ្នាំ២០២៤ របស់សមាគមឧកញ៉ាកម្ពុជានារសៀលថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤នៅសណ្ឋាគារហ្គាឌិនស៊ីធី។

ក្នុងឱកាសនោះដែរឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការបានសម្តែងនូវការអបអរសាទរនិងការវាយតម្លៃខ្ពស់ជូនចំពោះសមាគមឧកញ៉ាកម្ពុជាដែលបានបន្តរីកលូតលាស់ជាលំដាប់និងជាពិសេសបានសម្រេចនូវសមិទ្ធផលជាច្រើនជូនសង្គមជាតិតាមរយៈកិច្ចសហការក្នុងភាពជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការជំរុញលើកកម្ពស់សេដ្ឋកិច្ចសកម្មភាពពាណិជ្ជកម្ម និងវិនិយោគ ព្រមទាំងសកម្មភាពផ្សេងៗទៀត រួមទាំងសកម្មភាពមនុស្សធម៌នានា ដើម្បីជាប្រយោជន៍ដល់សង្គមជាតិ។











ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការបានបន្ថែមថាការរៀបចំ និងកិច្ចដំណើរការសន្និបាតលើកទី១ របស់សមាគមឧកញ៉ាកម្ពុជាប្រកបដោយភាពជោគជ័យនាពេលនេះគឺជាបង្គោលចរសំខាន់មួយដែលឆ្លុះបញ្ចាំងពីឧត្តមភាព និងវឌ្ឍនភាពគួរជាទីមោទននៃការកសាងនិងចងក្រងសហគមន៍ឧកញ៉ាដែលជាគំនិតផ្តួចផ្តើមរបស់លោកអ្នកឧកញ៉ាលី យ៉ុងផាត់ និងបាននិងកំពុងក្លាយជាសសរស្តម្ភដ៏សំខាន់មួយក្នុងការចូលរួមអភិវឌ្ឍ និងកសាងជាតិ។

ដោយសង្កេតឃើញពីតួនាទី និងមុខងារដ៏សំខាន់របស់សមាគមឧកញ៉ាកម្ពុជា និងក្នុងនាមជាប្រធានគណៈកម្មការអន្តរក្រសួងពិនិត្យ និងវាយតម្លៃលើសំណើសុំគោរមងារនិងការបញ្ចប់គោរមងារឧកញ៉ាឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ វង្សី វិស្សុត បានផ្តល់នូវអនុសាសន៍មួយចំនួន និងស្នើសុំកិច្ចសហការពីសមាគមឧកញ៉ាកម្ពុជា ដូចខាងក្រោម ៖

១. គោរមវន្តទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា របស់ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់នូវសីលធម៌ល្អប្រកបមុខរបរស្របច្បាប់និងចៀសវាងសកម្មភាពណាដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់គោរមងារឧកញ៉ា

២. ចលនាគោរមវន្តដែលជាសមាជិករបស់សមាគម ឱ្យចូលរួមកាន់តែសកម្មភាពថែមទៀត ក្នុងការអភិវឌ្ឍ និងកសាងជាតិ មានជាអាទិ៍ ការផ្តល់អំណោយជាថវិកា និងការចូលរួមបរិច្ចាគធនធានទ្រព្យសម្បត្តិ សម្ភារៈបរិក្ខារនានាជូនរដ្ឋ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាដែលក្នុងនោះមានដូចជា ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ ប្រព័ន្ធធារាសាស្ត្រ វត្តអារាម អគារសាធារណៈជាដើម

៣. ជួយរាជរដ្ឋាភិបាលលើការពិនិត្យ និងវាយតម្លៃចំពោះសំណើសុំផ្តល់គោរមងារឧកញ៉ា ឱ្យស័ក្តិសមស្របតាមគុណបំណាច់របស់គោរមវន្ត ក្នុងការចូលរួមអភិវឌ្ឍ និងកសាងជាតិ ក៏ដូចការបញ្ចប់គោរមងារឧកញ៉ា ក្នុងករណីប្រព្រឹត្តបទល្មើសនានាដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ឧកញ៉ា

៤. ក្នុងនាមជាស្ថាប័នតែមួយគត់ដែលតំណាងឱ្យគោរមវន្តទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សមាគមឧកញ៉ាកម្ពុជាត្រូវខិតខំប្រឹងប្រែងលើកកម្ពស់កិត្យានុភាពរបស់ខ្លួន ដើម្បីកៀរគរសមាជិកឱ្យកាន់តែច្រើន និងលើកកម្ពស់ភាពជាតំណាងរបស់ខ្លួនជូនសហគមន៍ឧកញ៉ាទាំងមូល

៥. សមាគមឧកញ៉ាកម្ពុជាត្រូវរៀបចំផែនការសកម្មភាពការងារសង្គម និងសប្បុរសធម៌ ជាពិសេសពន្លឿនការបង្កើតមូលនិធិសមាគមឧកញ៉ាកម្ពុជាដោយធានាឱ្យសមាជិក-សមាជិកាគ្រប់រូបមានឱកាសចូលរួមក្នុងសកម្មភាពទាំងនោះ ហើយមានអ្នកទទួលផលច្រើនពីគ្រប់មជ្ឈដ្ឋាន ដើម្បីលើកកម្ពស់សក្តានុពល និងកិត្យានុភាពរបស់សមាគម

៦. សមាគមឧកញ៉ាកម្ពុជាត្រូវរៀបចំយន្តការ និងមានកម្មវិធីច្បាស់លាស់ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងផង និងភាពជាដៃគូផងនៅក្នុងទីផ្សារសកម្មភាពពាណិជ្ជកម្មនិងការវិនិយោគក្នុងស្រុកនិងទាក់ទាញការវិនិយោគពីក្រៅប្រទេសមកប្រទេសកម្ពុជា

៧. សមាគមឧកញ៉ាកម្ពុជាគួរបន្តសហការឱ្យកាន់តែសកម្មជាមួយរាជរដ្ឋាភិបាលដើម្បីចូលរួមក្នុងការកែលម្អបរិយាកាសធុរកិច្ចនិងកសាងបរិយាកាសដែលមានភាពទាក់ទាញនិងអំណោយផលដល់សកម្មភាពអាជីវកម្មសំដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច ប្រកបដោយភាពធន់ និងបរិយាបន្ន។

ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតលើកទី១ឆ្នាំ២០២៣និងទិសដៅផែនការឆ្នាំ២០២៤របស់សមាគមឧកញ៉ាកម្ពុជា ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់កិត្តិយសប្រគល់នូវលិខិតថ្លែងអំណរគុណដល់អ្នកឧកញ៉ា ឧកញ៉ា និងលោកលោកស្រីជាថ្នាក់ដឹកនាំនិងតំណាងក្រុមហ៊ុននានាដែលបានចូលរួមឧបត្ថម្ភដល់ពិធីសន្និបាតលើកទី១និងពិធីពិសាអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជាដែលរួមមានកញ្ចប់មាសចំនួន ២៣ក្រុមហ៊ុន កញ្ចប់ប្រាក់ ១៩ក្រុមហ៊ុន និងកញ្ចប់សំរឹទ្ធ ១១ក្រុមហ៊ុន។
























## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីពិសារអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជា

នាល្ងាចថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានកិត្តិយស នៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីអបអរសាទរសន្និបាតលើកទី១ និងពិសាអាហារសាមគ្គីមហាគ្រួសារឧកញ៉ាកម្ពុជាដែលមានការចូលរួមពីសំណាក់ឥស្សរជនជាន់ខ្ពស់ជាថ្នាក់ដឹកនាំរាជរដ្ឋាភិបាលសមាជិកសមាគមឧកញ៉ាកម្ពុជាតំណាងវិស័យឯកជន គោរមវន្តជាភ្ញៀវកិត្តិយស ព្រមទាំងភ្ញៀវជាតិ អន្តរជាតិប្រមាណជាជាង ៦០០រូប។








**សម្តេចតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា ក្នុងនាមជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា **សម្តេច** សូមអបអរសាទរ និងកោតសរសើរចំពោះការរៀបចំទាំងឡាយរបស់សមាគមឧកញ៉ាកម្ពុជាទាំងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ព្រមទាំងកិច្ចការពាក់ព័ន្ធរបស់សមាគមឧកញ៉ា និងការរៀបរយនូវឯកសណ្ឋានប្រកបដោយកិត្តិយសក្តិសមជាសមាគមមួយដែលបានចូលរួមចំណែកយ៉ាងធំធេងជាមួយរាជរដ្ឋាភិបាលដើម្បីការអភិវឌ្ឍប្រទេសជាតិ។ **សម្តេចតេជោ** បានមានប្រសាសន៍បញ្ជាក់ទៀតថា **សម្តេច** តែងតែចាត់ទុកថា វិស័យឯកជនគឺជាក្បាលរថភ្លើងក្នុងការចូលរួមកសាងកំណើនសេដ្ឋកិច្ចជាតិ ខណៈដែលរដ្ឋាភិបាលគឺជាសេដ្ឋវិទូក្នុងការដឹកនាំប្រទេសជាតិ។ចាប់តាំងពីយុទ្ធសាស្ត្រចតុកោណរហូតដល់បញ្ចកោណដំណាក់កាលទី១គឺបានរក្សានូវកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពនៅកម្ពុជា នាទីពីរសំខាន់គឺជំរុញកំណើនសេដ្ឋកិច្ចតាមរយៈតួនាទីរបស់វិស័យឯកជននេះឯង។ **សម្តេចតេជោ**បានថ្លែងថា សេដ្ឋកិច្ចមានការលូតលាស់ត្រូវជំរុញដោយអ្នកដែល

ទី២ គឺជាអ្វីដែលអ្នកវិនិយោគកំពុងដោះស្រាយការងាររាប់ពាន់កន្លែងនៅក្នុងប្រទេសកម្ពុជា។

**សម្តេចតេជោ**ក៏បានមានប្រសាសន៍រំលឹកថាមានថវិកាប្រមាណពីររយលានដុល្លារដែលសប្បុរសជនជាឧកញ៉ា និងអ្នកឧកញ៉ានៅកម្ពុជាបានជួយនៅអំឡុងវិបត្តិកូវីដដើម្បីទិញវ៉ាក់សាំង និងទិញមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺកូវីដនៅអំឡុងពេលប្រឈមខ្លាំងខណៈប្រទេសផ្សេងៗជាច្រើនទទួលបានថវិកាតិចតួចប៉ុណ្ណោះពីសប្បុរសជននៅក្នុងប្រទេសខ្លួន។

ក្នុងឱកាសនោះដែរ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងនូវសុន្ទរកថាអំពីការជីកព្រែកជីក "**ហ្វូណនតេជោ**" ដែលមានសារៈសំខាន់ជាច្រើនពោលគឺក្រោយគម្រោងព្រែកជីក "**ហ្វូណនតេជោ**" បានសម្រេចជាស្ថាពរហើយនោះគឺនឹងលែងមានការខ្វះខាតទឹកប្រើប្រាស់និងសម្រាប់ស្រោចស្រពដំណាំរបស់ប្រជាពលរដ្ឋទៀតនោះឡើយជាពិសេសគឺបងប្អូនប្រជាពលរដ្ឋដែលរស់នៅតំបន់ទិសនិរតីតែម្តង ព្រមទាំងជាផ្លូវតភ្ជាប់ដោយផ្ទាល់ទៅកាន់សមុទ្រដោយមិនឆ្លងកាត់ប្រទេសដទៃគឺមិនឆ្លងកាត់ប្រទេសវៀតណាម ដែលតម្រូវឱ្យមានការបង់ថ្លៃពេលឆ្លងកាត់ប្រទេសគេនោះ។

**សម្តេចតេជោ**បានប្រកាសយ៉ាងដាច់ណាត់ថាកម្ពុជាគ្មានការរាថយនោះឡើយចំពោះគម្រោងធ្វើ"**ហ្វូណនតេជោ**" ហើយសម្តេចក៏បានប្រកាសផងដែរថាកម្ពុជាក៏គ្មានអ្វីចាំបាច់ត្រូវចចារ និងពិគ្រោះយោបល់ជាមួយអ្នកណានោះដែរទាក់ទងនឹងគម្រោងនេះ។ **សម្តេចតេជោ ហ៊ុន សែន** ក៏បានប្រកាសអំពាវនាវដល់ជនរួមជាតិទាំងអស់គាំទ្រគម្រោងព្រែកជីកហ្វូណនតេជោខណៈគម្រោងនេះនឹងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាកាន់តែរីកចម្រើនបន្ថែមទៀតនិងថែមទាំងកាត់បន្ថយការបង់ពន្ធទៅភាគីវៀតណាមផងដែរតាមរយៈការដឹកជញ្ជូនតាមផ្លូវទឹកនេះ។








បន្ទាប់ពីបញ្ចប់សុន្ទរកថា **សម្តេចតេជោ** បានផ្តល់កិត្តិយសប្រគល់ជូននូវព្រះរាជក្រឹត្យត្រាស់បង្គាប់ផ្តល់គោរមងារជា«**លោកអ្នកឧកញ៉ា**»ជូនដល់គោរមវន្តចំនួន**៧**រូបមានដូចជា៖**លោកអ្នកឧកញ៉ាលីយ៉ុងផាត់,លោកអ្នកឧកញ៉ា ពុង ឃាវសែ, លោកអ្នកឧកញ៉ា លី ហួរ, លោកអ្នកឧកញ៉ា ស៊ី គង់ទ្រីវ, ជំទាវលោកអ្នកឧកញ៉ា ភូ ហុងស៊្វន ស៊ីគង់ទ្រីវ ជំទាវលោកអ្នកឧកញ៉ា ភាព ហៀក និងលោកអ្នកឧកញ៉ា លាង យុន។**















ជាកិច្ចបន្ត **សម្តេចតេជោ** បានផ្តល់កិត្តិយសថតរូបជាអនុស្សាវរីយ៍ជាមួយនឹងគោរមវន្តដែលទទួលបានគោមរមងារជាលោកអ្នកឧកញ៉ាទាំង៧រូបព្រមទាំងជាមួយអនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលរបស់សមាគមឧកញ៉ាកម្ពុជាទាំង ៣២រូប និងជាមួយសមាជិកសកម្ម សមាជិកទ្រទ្រង់នៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀតផងដែរ។

បន្ទាប់មក **សម្តេចតេជោ** បានផ្តល់កិត្តិយសចូលរួមទស្សនាទស្សនីយភាពនានានៃការសម្តែងសិល្បៈរួមមានរបាំប្រជាប្រិយការច្រៀងកម្សាន្តអមដោយការទទួលទានអាហារសាមគ្គីជាមួយមហាគ្រួសាឧកញ៉ាកម្ពុជាប្រកបដោយភាពស្និទ្ធស្នាល និងកិត្តិយសដ៏ឧដុង្គឧត្តមក្រៃលែង។

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ និងលោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីពិព័រណ៍រថយន្តលើកទី១ នៅអគារ ដឺ ព្រេមៀ សេនធ័រ សែនសុខ

នាព្រឹកថ្ងៃសៅរ៍ ៤រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវអ្នកឧកញ៉ា គីម ហ៊ាង ព្រមទាំងអ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីពិព័រណ៍រថយន្ត (Auto Show) លើកទី១ ដែលបានរៀបចំឡើងនៅអគារ ដឺ ព្រេមៀ សេនធ័រ សែនសុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ព្រមទាំងមានចូលរួមពីលោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, អ្នកឧកញ៉ា សេង ញ៉ក់ អគ្គនាយកក្រុមហ៊ុន គ្រី អេធីវ លីវីង ឯ.ក រួមទាំងភ្ញៀវកិត្តិយសជាច្រើនរូបទៀត។












នាឱកាសនោះឯកឧត្តមឧបនាយករដ្ឋមន្ត្រីហ៊ុនម៉ានីបានថ្លែងថាការកើនឡើងនៃក្រុមហ៊ុននាំចូលនិងក្រុមហ៊ុនដំឡើងរថយន្តនៅកម្ពុជាកើតឡើងពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបើកចំហរសេដ្ឋកិច្ចទីផ្សារសេរីនិងបើកទូលាយឱ្យមានការវិនិយោគក្នុងប្រទេសកម្ពុជាដើម្បីកំណើនសេដ្ឋកិច្ចបង្កើតការងារ និងឆ្លើយតបតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋខ្មែរផងដែរ។

ឯកឧត្តមបានបន្ថែមថា ការរៀបចំពិព័រណ៍រថយន្តនេះជាផ្នែកមួយយ៉ាងសំខាន់នៃការចូលរួមចំណែករបស់ផ្នែកឯកជនក្នុងការបង្ហាញឱ្យកាន់តែច្បាស់ពីសក្តានុពលនៃសេដ្ឋកិច្ចកម្ពុជាជាពិសេសការរីកចម្រើននៃវិស័យយានយន្តនៅកម្ពុជាដោយលោកសង្ឃឹមយ៉ាងមុតមាំថាគំនិតផ្តួចផ្តើមនេះនឹងបន្តកើតមានជាបន្តបន្ទាប់ទៀតផងដែរ។

បើតាមការបញ្ជាក់ពីអ្នកឧកញ៉ា សេង ញ៉ក់ ការរៀបចំពិព័រណ៍រថយន្តនេះមិនមែនដើម្បីតែការលក់រថយន្ត នឹងការធ្វើអាជីវកម្មផ្សព្វផ្សាយប៉ុណ្ណោះទេតែដើម្បីបង្កើតទំនាក់ទំនងជិតស្និទ្ធនិងការស្វែងយល់ស៊ីជម្រៅរវាងដៃគូទាំងអស់ដែលពាក់ព័ន្ធក្នុងវិស័យរថយន្តរួមមាន៖ ទំនាក់ទំនងរវាងក្រុមហ៊ុនផលិតនិងអតិថិជនដែលជាអ្នកប្រើប្រាស់ទំនាក់ទំនងរវាងរដ្ឋាភិបាល និងវិស័យឯកជន ទំនាក់ទំនងរវាងក្រុមហ៊ុននាំចូលផ្តាច់មុខនៅប្រទេសកម្ពុជា និងមេក្រុមហ៊ុននៅក្រៅប្រទេស ទំនាក់ទំនងរវាងវិស័យរថយន្តនិងវិស័យពាក់ព័ន្ធផ្សេងៗដូចជាវិស័យធនាគារវិស័យធានារ៉ាប់រងជាដើម ហើយពិព័រណ៍រថយន្តនេះក៏ដើម្បីឱ្យអ្នកទិញរថយន្តទទួលបានព័ត៌មានច្បាស់អំពីរថយន្តពីខាងផ្នែករោងចក្រផលិតនិងក្រុមហ៊ុនចែកចាយមុននឹងទិញរថយន្តផងដែរ។















## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ក្នុងបេសកកម្មនៅប្រទេសជប៉ុនចាប់ថ្ងៃទី៦-១០ ខែឧសភា ឆ្នាំ២០២៤

ដោយមានសំណើសុំចាត់តាំងប្រតិភូពី **ឯកឧត្តម ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា ធ្វើជាតំណាងប្រធាន និងដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ៥រូបដើម្បីចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី៦-១០ ខែឧសភា ឆ្នាំ២០២៤ ក្នុងគោលបំណងផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពអំពីបរិយាកាសវិនិយោគ និងកាលានុវត្តភាពធុរកិច្ចនៅកម្ពុជា។

នៅក្នុងដំណើរបេសកកម្មនេះ ប្រតិភូសមាគមឧកញ៉ាកម្ពុជានឹងចូលរួមក្នុងកម្មវិធីសំខាន់ៗដូចជា៖

### ជំនួបពិភាក្សាការងាររវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន (AJC) នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤













នាព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ព្រមជាមួយនឹងឯកឧត្តម ទុយ រី ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន និងគណៈប្រតិភូកម្ពុជា ចូលជួបពិភាក្សាការងារជាមួយ លោក Kunihiko Hirabayashi អគ្គលេខាធិការមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន ឬ ASEAN-Japan Centre (AJC) ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការក៏ដូចជាបទបង្ហាញអំពីបច្ចុប្បន្នភាពនៃបរិយាកាសវិនិយោគនៅកម្ពុជាទាំងលើទិដ្ឋភាពច្បាប់ ពន្ធដា និងកត្តាជាច្រើនទៀតដែលមានភាពបើកចំហ ទាក់ទាញ ក៏ដូចជាងាយស្រួលសម្រាប់ការបណ្តាក់ទុនវិនិយោគលើគ្រប់វិស័យ។

ជាមួយគ្នានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានធ្វើបទបង្ហាញ និងពន្យល់យ៉ាងលម្អិតអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលលើការធ្វើឱ្យប្រសើរឡើងផ្នែកភស្តុភារកម្មតាមរយៈគម្រោងព្រែកជីក "**ហ្វូណនតេជោ**" ដែលជាគម្រោងប្រវត្តិសាស្ត្ររបស់កម្ពុជាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ដ៏ធំធេងទាំងលើផ្នែកធារាសាស្ត្រវារីវប្បកម្មជាពិសេស វិស័យពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញដែលអាចផ្តល់នូវផលចំណេញទាំងពេលវេលា និងការចំណាយថ្លៃដើម។ល។

ជាការឆ្លើយតប លោកអគ្គលេខាធិការបានស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងគណៈប្រតិភូកម្ពុជាដែលបានជ្រើសយកប្រទេសជប៉ុនជាគោលដៅនៃបេសកកម្មដ៏ឧត្តុង្គឧត្តមនាពេលនេះហើយលោកអគ្គលេខាធិការបានបង្ហាញនូវជំនឿចិត្តយ៉ាងមុតមាំថារាជរដ្ឋាភិបាលនីតិកាលទី៧នឹងទាក់ទាញបាននូវគម្រោងវិនិយោគមកពីគ្រប់ទិសទីឱ្យកាន់តែមានកំណើនជាលំដាប់។

## ជំនួបពិភាក្សាការងាររវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយសម្ព័ន្ធសភាមិត្តភាពកម្ពុជា-ជប៉ុន











នាល្ងាចថ្ងៃអង្គារ ទី៧ ខែឧសភា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជាបានបន្តដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចូលជួបពិភាក្សាការងារជាមួយឯកឧត្តមImamura Masahiroប្រធានសម្ព័ន្ធសភាមិត្តភាពកម្ពុជា-ជប៉ុន ក្នុងគោលបំណងផ្លាស់ប្តូរយោបល់ស្តីពីកិច្ចសហប្រតិបត្តិការនាពេលអនាគតរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសម្ព័ន្ធសភាមិត្តភាពកម្ពុជា-ជប៉ុន។

ក្នុងជំនួបនាឱកាសនេះភាគីទាំងពីរបានពិភាក្សាអំពីការបង្កើតកិច្ចសហការលើការជួយបញ្ជ្រាបការឈ្វេងយល់អំពីបរិយាកាសវិនិយោគក៏ដូចជាកាលានុវត្តភាពវិនិយោគនៅកម្ពុជាទៅកាន់សហគមន៍ធុរកិច្ចនានានៅប្រទេសជប៉ុនសំដៅទាក់ទាញសហគ្រាសដែលមានសក្តានុពលឱ្យមកពង្រីកខ្សែច្រវាក់ផលិតកម្មឬខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួនមកកាន់កម្ពុជានាពេលអនាគត។

# សិក្ខាសាលាស្តីពីការវិនិយោគនៅកម្ពុជាដើម្បីផ្សព្វផ្សាយអំពីសក្តានុពល និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ទៅកាន់សហគ្រាសរបស់ជប៉ុន












នាព្រឹកថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម «សិក្ខាសាលាស្តីពីការវិនិយោគនៅកម្ពុជាដើម្បីផ្សព្វផ្សាយអំពីសក្តានុពលនិងកាលានុវត្តភាពវិនិយោគនៅកម្ពុជាទៅកាន់សហគ្រាសរបស់ជប៉ុន» ដែលត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយមានកិច្ចសហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន (AJC) និងអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន(JETRO) នៅសាលមហោស្រពនៃសាកលវិទ្យាល័យអង្គការសហប្រជាជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

សិក្ខាសាលានេះមានគោលបំណងផ្សព្វផ្សាយអំពីសក្តានុពលនិងកាលានុវត្តភាពវិនិយោគនៅកម្ពុជាទៅកាន់សហគ្រាសរបស់ជប៉ុនដោយមានការអញ្ជើញចូលរួមពីសំណាក់តំណាងស្ថានតំណាងបរទេសប្រចាំប្រទេសជប៉ុន ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មនៃប្រទេសជប៉ុន សម្ព័ន្ធសភាមិត្តភាពកម្ពុជា-ជប៉ុន សមាគមជប៉ុន-កម្ពុជា និងវិស័យឯកជនសរុបប្រមាណ ១៥០រូប។

ក្នុងឱកាសនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានរំលេចអំពីសក្តានុពលវិជ្ជមានរបស់ព្រះរាជាណាចក្រកម្ពុជា មានជាអាទិ៍ស្ថិរភាពនយោបាយ,ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចដែលមានលំនឹងវិជ្ជមាន,កម្លាំងពលកម្មវ័យក្មេងប្រកបដោយថាមវន្ត,រាជរដ្ឋាភិបាលដែលមានទំនោរគាំទ្រដល់ការរីកលូតលាស់នៃធុរកិច្ច,របបវិនិយោគដែលមានភាពទាក់ទាញ និងអនុគ្រោះ និងហេដ្ឋារចនាសម្ព័ន្ធអន្តរមធ្យោបាយដែលបាន និងកំពុងអភិវឌ្ឍឱ្យកាន់តែមានភាពតភ្ជាប់ និងប្រទាក់ក្រឡា។

ជាមួយគ្នានេះ វាគ្មិនមកពីវិស័យឯកជនក៏បានចូលរួមវេទិកាពិភាក្សា ស្ដីពីសក្ដានុពលវិនិយោគលើវិស័យថ្មីៗនៅកម្ពុជាដោយបានគូសបញ្ជាក់អំពីភាពងាយស្រួលក្នុងការប្រកបអាជីវកម្មនៅកម្ពុជាពិពិធភាពនៃសកម្មភាពវិនិយោគដែលពោរពេញដោយឱកាសនិងការគាំទ្រផ្នែកគោលនយោបាយប្រកបដោយបុរេសកម្មពីសំណាក់រាជរដ្ឋាភិបាលលើអនុវិស័យថាមពលកកើតឡើងវិញខ្សែច្រវាក់ផលិតកម្មបៃតង និងសេដ្ឋកិច្ចឌីជីថលដែលកំពុងតែដើរស្របនឹងនិន្នាការតំបន់ និងសកល។

សូមជម្រាបជូនផងដែរថា ស្របពេលនៃព្រឹត្តិការណ៍ខាងលើ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានផ្ដល់កិត្តិយសអញ្ជើញបើកកម្មវិធីផ្គូផ្គងធុរកិច្ចរវាងសមាគមឧកញ៉ាកម្ពុជា សភាពាណិជ្ជកម្មកម្ពុជា និងសមាគមកម្ពុជា-ជប៉ុនផងដែរ។

## ជំនួបពិភាក្សាការងាររវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាមួយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន ( JETRO ) និង ជំនួបផ្គូផ្គងធុរកិច្ចកម្ពុជា-ជប៉ុន








នារសៀលថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម "ជំនួបផ្គូផ្គងធុរកិច្ច" រវាងសហគមន៍ធុរកិច្ចកម្ពុជា និងជប៉ុន នៅទីស្នាក់កណ្ដាលនៃអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន (JETRO) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អមដោយ ឯកឧត្តម ទុយ រី ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន។

ជំនួបផ្គូផ្គងធុរកិច្ចនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សារភ្ជាប់ទំនាក់ទំនងសហគមន៍ធុរកិច្ចទាំងពីរឱ្យកាន់តែជិតស្និទ្ធថែមមួយកម្រិតទៀតនិងដើម្បីជាឱកាសសម្រាប់វិនិយោគិននៃប្រទេសទាំងពីរធ្វើការប្រាស្រ័យទាក់ទងគ្នា និងសិក្សាស្វែងរកអត្ថប្រយោជន៍រួមនៃការវិនិយោគដ៏មានសក្ដានុពលទៅវិញទៅមក។

មានមតិក្នុងជំនួបខាងលើឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណជូនចំពោះភាគីមិត្តដែលបានរៀបចំកម្មវិធីផ្គូផ្គងដ៏មានតម្លៃនាឱកាសបេសកកម្មគោះទ្វារវិនិយោគរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានាពេលនេះ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានគូសបញ្ជាក់ផងដែរថាសហគ្រាសដែលបានចូលរួមក្នុងជំនួបផ្តួងសុទ្ធសឹងតែជាសហគ្រាសដែលបានចូលរួមក្នុងសិក្ខាសាលាវិនិយោគកម្ពុជាឆ្នាំ២០២៣ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ នៅទីក្រុងតូក្យូ។ ក្នុងស្មារតីនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបង្ហាញក្តីសង្ឃឹមយ៉ាងមុតមាំថា វិស័យឯកជនដែលបានចូលរួមនឹងខិតខំក្តាប់ជាប់នូវឱកាសមាសពេជ្រនេះ  សំដៅទាក់ទាញសហគ្រាសដែលមានវត្តមានឱ្យទៅបណ្តាក់ទុនវិនិយោគនៅលើទឹកដីកម្ពុជា។

គួរជម្រាបជូនផងដែរថាក្រុមហ៊ុនដែលបានអញ្ជើញចូលរួមក្នុងជំនួបផ្តួងខាងលើគឺជាក្រុមហ៊ុនដែលបាននិងកំពុងបណ្តាក់ទុនវិនិយោគលើវិស័យភស្តុភារកម្មកម្មន្តសាលអាលុយមីញ៉ូមកសិកម្មនិងកសិ-ឧស្សាហកម្មឱសថនិងព័ត៌មានវិទ្យានិងសារគមនាគមន៍។បន្ថែមទៀត អ្នកឧកញ៉ា ហ៊ុន ឡាក់  បានបន្តដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាចូលរួមជំនួបជាមួយលោក Ishiguro Norihiko ប្រធានអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន(JETRO) ក្នុងគោលបំណងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការចំពោះមុខរវាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង JETRO ក្នុងការទាក់ទាញ និងជំរុញវិនិយោគនៅកម្ពុជា។

មានប្រសាសន៍ក្នុងឱកាសនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណជូនចំពោះ JETRO សម្រាប់ការជួយគាំទ្រដល់សកម្មភាពជំរុញ  និងទាក់ទាញវិនិយោគនានាដែលផ្តួចផ្តើមឡើងដោយកម្ពុជា។ ទន្ទឹមនឹងនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានជម្រាបជូនភាគីមិត្តអំពីវឌ្ឍនភាពនៃការដោះស្រាយបញ្ហានានាដែលលើកឡើងដោយក្រុមហ៊ុនជប៉ុនក្នុងអំឡុងកិច្ចប្រជុំនៃគណៈកម្មាធិការចម្រុះកម្ពុជា–ជប៉ុនក្រោមក្របខណ្ឌនៃកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងជប៉ុនស្តីពីសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគ។

ជាកិច្ចបញ្ចប់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានស្នើភាគីមិត្តឱ្យបន្តផ្តល់កិច្ចសហការបន្ថែមសំដៅពន្លាតវិសាលភាពនៃកិច្ចសហប្រតិបត្តិការលើកិច្ចការវិនិយោគឱ្យកាន់តែសកម្ម និងគ្រប់ជ្រុងជ្រោយ ជាពិសេសការចែករំលែកបទពិសោធអំពីការរៀបចំមជ្ឈមណ្ឌលផ្តល់កិច្ចសម្រួលធុរកិច្ចដែល JETRO បានរៀបចំយ៉ាងជោគជ័យ សំដៅធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់កិច្ចសម្រួលវិនិយោគរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឱ្យកាន់តែល្អមួយកម្រិតទៀត។





## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមពិធី “ប្រកាសបើកឱ្យដំណើរការជាផ្លូវការសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គី”











នាល្ងាចថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមពិធី «ប្រកាសបើកឱ្យដំណើរការជាផ្លូវការសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គី» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបានប្រព្រឹត្តទៅនៅសាលសន្និបាត និងពិព័រណ៌កោះពេជ្រ។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានមានប្រសាសន៍ថាពិធីប្រកាសបើកឱ្យដំណើរការជាផ្លូវការសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជាបានសបញ្ជាក់យ៉ាងច្បាស់ពីសេចក្តីទុកចិត្តយ៉ាងមុតមាំពីវិស័យឯកជនចំពោះរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងជាការបង្ហាញនូវទឹកចិត្តដ៏ប្រពៃថ្លៃថ្លាក្នុងការរួមចំណែកជួយជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ក្នុងន័យនេះ ការបង្កើតឱ្យមានសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា គឺមានគោលបំណងក្នុងការប្រមូលផ្តុំនូវសមាសភាពសមាគមនីមួយៗរួមគ្នាជាថ្នាលធំមួយដើម្បីពង្រឹង និងពង្រីកសកម្មភាពទាក់ទាញវិនិយោគិនបរទេសមកពីគ្រប់ប្រទេសដើម្បីចូលមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជាជាអតិបរមា និងចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាសកម្មភាពវិជ្ជមានមួយជួយដល់ការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជា ព្រោះថាកំណើននៃការវិនិយោគ និងការធ្វើពាណិជ្ជកម្ម នឹងជួយបង្កើតឱកាសការងារយ៉ាងសន្ធឹកសន្ធាប់ជូនដល់ប្រជាជន ព្រមទាំងជំរុញការនាំចូលមកនូវជំនាញ និងបច្ចេកវិទ្យាថ្មីៗបន្ថែម ដែលកត្តាទាំងនេះសុទ្ធសឹងតែស្ថិតនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងអាណត្តិទី៧ នៃរដ្ឋសភា មានបាវចនា ចំនួន៥ គឺ «កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព» និងមានអាទិភាពគន្លឹះចំនួន៥ គឺ «មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា»។















# កិច្ចប្រជុំ គ.ព.វ.គ លើកទី៥ ដើម្បីពិភាក្សាសម្រេចលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីបែបបទនិងនីតិវិធី នៃការស្នើសុំ និងវាយតម្លៃក្នុងការផ្ដល់គោរមងារឧកញ៉ា និងការបញ្ចប់គោរមងារឧកញ៉ា













នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី ហួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដែលតំណាងឱ្យសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងពិនិត្យនិងវាយតម្លៃលើសំណើសុំគោរមងារ និងការបញ្ចប់គោរមងារឧកញ៉ា ( គ.ព.វ.គ ) ក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ព.វ.គ។ របៀបវារៈនៃកិច្ចប្រជុំដ៏សំខាន់នេះគឺដើម្បីពិភាក្សាសម្រេចលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីបែបបទនិងនីតិវិធីនៃការស្នើសុំ និងវាយតម្លៃក្នុងការផ្ដល់គោរមងារឧកញ៉ា និងការបញ្ចប់គោរមងារឧកញ៉ា។

ឯកឧត្តមប្រធានអង្គប្រជុំបានសម្ដែងនូវការស្វាគមន៍និងថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំលើកទី៤ដើម្បីបន្ថែមនិងពិភាក្សាសម្រេចចំណុចដែលនៅសេសសល់នៃមាត្រាមួយចំនួននៃអនុក្រឹត្យខាងលើ។ អង្គប្រជុំបានធ្វើការពិនិត្យ ពិភាក្សា ផ្ដល់យោបល់ និងឯកភាពសម្រេចលើចំណុចបន្ថែមនានាស្របតាមស្មារតីនៃអង្គប្រជុំដោយបានពិនិត្យ និងផ្ទៀងផ្ទាត់យ៉ាងយកចិត្តទុកទៅលើគ្រប់ទិដ្ឋភាព ក្នុងនោះមានទិដ្ឋភាពច្បាប់និងទិដ្ឋភាពជាក់ស្ដែងនៃគោរមវន្តជាពិសេសស្របតាមខ្លឹមសារនៃព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២២៥០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ស្ដីពីគោរមងារឧកញ៉ា។

នេះគឺជាលទ្ធផលថ្មីមួយទៀតដ៏ត្រចះត្រចង់សម្រាប់សមាគមឧកញ៉ាកម្ពុជាក្នុងឆ្នាំ២០២៤ ដែលជាស្ថាប័នតែមួយគត់តំណាងឱ្យគោរមវន្តទាំងអស់នៅកម្ពុជាបាននិងកំពុងចូលរួមយ៉ាងសស្រាក់ស្រាំ និងតស៊ូយ៉ាងស្វិតស្វាញ ដើម្បីការពារផលប្រយោជន៍ និងអត្ថប្រយោជន៍រួមរបស់សមាជិកស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## លោកអ្នកឧកញ៉ា លាង ឃុន តំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ ឧកញ៉ា គី ទីគា សមាជិកនៃសមាគមឧកញ៉ាកម្ពុជា








នារសៀលថ្ងៃអាទិត្យ ១២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លាង ឃុន អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាល និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ចំនួន ២៧រូប បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ ឧកញ៉ា គី ទីគា សមាជិកនៃសមាគមឧកញ៉ាកម្ពុជា ដែលបានទទួលមរណភាពកាលពីថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ១១:០៨ នាទីយប់ក្នុងជន្មាយុ ៦៥ឆ្នាំដោយរោគាពាធ។

ក្នុងវេលាប្រកបដោយទុក្ខព្រួយដ៏សោកសង្រេងជាទីបំផុតនេះ លោកអ្នកឧកញ៉ា លាង ឃុន បានចូលរួមរំលែកមរណទុក្ខដ៏ក្រៀមក្រំបំផុតជាមួយលោកជំទាវលី សុខខេងព្រមទាំងក្រុមគ្រួសារដោយសេចក្ដីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ឧត្តមស្វាមីក៏ដូចជាអ្នកមានគុណមួយរូបជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅពោរពេញដោយព្រហ្មវិហារធម៌និងបានលះបង់បូជាកម្លាំងកាយកម្លាំងចិត្តគ្រប់សព្វបែបយ៉ាងក្នុងការបីបាច់ថែរក្សាបុត្រា បុត្រី ចៅប្រុស ចៅស្រី ឱ្យក្លាយជាពលរដ្ឋដ៏ល្អសម្រាប់សង្គមជាតិ។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ ឧកញ៉ា គី ទីគា សូមបានបដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំកិច្ចប្រជុំ ក្រុមប្រឹក្សាភិបាលលើកទី៤ អាណត្តិទី១



នាថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ នាទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា នៃសណ្ឋាគារភ្នំពេញ សមាគមឧកញ៉ាកម្ពុជា បានបើកកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៤ អាណត្តិទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកអ្នកឧកញ៉ា លី យ៉ុងផាត់ប្រធានក្រុមប្រឹក្សាភិបាលនិងជាប្រធានអង្គប្រជុំដោយមានវត្តមានចូលរួមពីសំណាក់លោកអ្នកឧកញ៉ានិងអ្នកឧកញ៉ាជាអនុប្រធាននិងជាសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមចំនួន ២៤រូប។

កិច្ចប្រជុំប្រចាំត្រីមាសឆ្នាំនេះបានធ្វើឡើងស្របតាមលក្ខន្តិកៈរបស់សមាគមដើម្បីពិនិត្យ ពិភាក្សា និងអនុម័តលើរបៀបវារៈសំខាន់ៗរួមមាន៖

១. ប្រភពនិងការប្រមូលមូលនិធិ និងគម្រោងសម្ពោធសមាគមមូលនិធិឧកញ៉ាកម្ពុជា

២. ការរៀបចំសន្និបាតលើកទី២ របស់សមាគមឧកញ៉ាកម្ពុជា

៣.ផ្សេងៗ, ដែលក្នុងនោះមានដូចជាកិច្ចពិភាក្សា និងបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលថ្មីបន្ថែម, ការកំណត់ពេលវេលាប្រគល់ថវិកាជូនកាកបាទក្រហមកម្ពុជា, ផែនការរៀបចំវេទិកាធុរកិច្ចជាមួយបណ្ដាស្ថាប័នអន្តរជាតិនានា, និងការរៀបចំពិធីសំណេះសំណាលជាមួយនឹងសម្ដេចធិបតីនាយករដ្ឋមន្ត្រីជាដើម។

ជាកិច្ចចាប់ផ្ដើម លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងមូលដែលបានចំណាយពេលដ៏មានតម្លៃចូលរួមកិច្ចប្រជុំដ៏មានសារៈសំខាន់នាថ្ងៃនេះ។ ជាកិច្ចបន្ទាប់អ្នកឧកញ៉ាហ៊ុន ឡាក់អគ្គលេខាធិការបានធ្វើបទបង្ហាញជូនអង្គប្រជុំទាំងមូលទៅតាមរបៀបវារៈនីមួយៗ ដោយសមាជិកអង្គប្រជុំបានចូលរួមជជែកពិភាក្សា និងផ្ដល់ធាតុចូលសំខាន់ៗទៅលើរបៀបវារៈទាំងនោះយ៉ាងផុសផុល និងយកចិត្តទុកដាក់ជាទីបំផុត។

ជាលទ្ធផល កិច្ចប្រជុំបានសម្រេចឯកភាពលើរបៀបវារៈនីមួយៗដូចខាងក្រោម៖

**របៀបវារៈទី១៖**អង្គប្រជុំបានសម្រេចចុះបញ្ជីនិងតម្កល់លក្ខន្តិកៈនៃសមាគមមូលនិធិឧកញ៉ាកម្ពុជានៅក្រសួងមហាផ្ទៃដើម្បីបំពេញកាតព្វកិច្ចឱ្យបានត្រឹមត្រូវស្របតាមច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ អង្គប្រជុំក៏បានកំណត់ប្រ ភព និងទំហំមូលនិធិដើម្បីរក្សាបាននូវនិរន្តរភាពមូលនិធិសម្រាប់ទ្រទ្រង់សកម្មភាពសប្បុរសធម៌នានាផងដែរ ពាក់ព័ន្ធនឹងការសម្ពោធសមាគមមូលនិធិឧកញ៉ាកម្ពុជានេះ អង្គប្រជុំបានឯកភាពរៀបចំក្នុងពេលសន្និបាត លើកទី២របស់សមាគម ដែលគ្រោងនឹងរៀបចំនាចុងខែកុម្ភៈ ឆ្នាំ២០២៥ ខាងមុខនេះ។

**របៀបវារៈទី២៖**អង្គប្រជុំបានឯកភាពលើការកំណត់កាលបរិច្ឆេទទីតាំងសមាសភាពចូលរួមនិងរបៀបវារៈនៃសន្និបាតលើកទី២ ដោយប្រារព្ធធ្វើឡើងពេញមួយថ្ងៃ នាចុងខែកុម្ភៈ ឆ្នាំ២០២៥ ក្រោមអធិបតីភាពឥស្សរជនជាន់ខ្ពស់ និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា។

**ចំពោះរបៀបវារៈផ្សេងៗ ៖**

**ក.**អង្គប្រជុំបានសម្រេចជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលថ្មីបន្ថែមតាមរយៈការបោះឆ្នោតជ្រើសរើសបេក្ខភាពដែលបានដាក់ពាក្យឈរឈ្មោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌បំផុតដែលជាលទ្ធផលអង្គប្រជុំជ្រើសរើសបានសមាជិកក្រុមប្រឹក្សាភិបាលចំនួន ១៣រូប ដើម្បីចូលរួមជួយដល់រាល់សកម្មភាពរបស់សមាគមឱ្យកាន់តែមានស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ស្របតាមភាពរីកចម្រើន និងការងារដ៏មមាញឹករបស់សមាគមនាពេលបច្ចុប្បន្ន និងទៅអនាគត។

**ខ.**បន្ថែមលើនេះ អង្គប្រជុំក៏បានឯកភាពលើការកំណត់កាលបរិច្ឆេទ ទីតាំង សមាសភាពចូលរួម និងរបៀបវារៈនៃការរៀបចំវេទិកាធុរកិច្ចនានាដោយសហការជាមួយបណ្តាសមាគម សភាពាណិជ្ជកម្ម និងស្ថាប័នអន្តរជាតិនានា ដែលក្នុងនោះក៏នឹងមានការរៀបចំជំនួបផ្គូផ្គងធុរកិច្ចរវាងសមាជិកសមាគម និងក្រុមហ៊ុនបរទេសធំៗក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី។

**គ.**ជាចុងក្រោយនៃកិច្ចប្រជុំអង្គប្រជុំក៏បានឯកភាពលើការកំណត់កាលបរិច្ឆេទ និងសមាសភាពចូលរួមយកថវិកាដែលប្រមូលបានពីសមាជិករួមនឹងថវិការបស់សមាគមទៅប្រគល់ជូនកាកបាទក្រហមកម្ពុជា។

កិច្ចប្រជុំបានបិទបញ្ចប់នៅវេលាម៉ោង ១៨:០០នាទី ក្នុងកាលបរិច្ឆេទថ្ងៃខែឆ្នាំដដែល ដោយទទួលបានលទ្ធផលផ្លែផ្កាក្រោមបរិយាកាសសប្បាយរីករាយ និងស្និទ្ធស្នាលបំផុត។

























## អ្នកឧកញ៉ា សៀ ឫទ្ធី ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់ធុរកិច្ច (Business Lunch) រវាងថ្នាក់ដឹកនាំក្រុមហ៊ុន សហគ្រាស និងធុរជននៃប្រទេសកម្ពុជា និងតួកគី

យោងតាមសំណើពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា សៀ ឫទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា ធ្វើជាតំណាងលោកអ្នកឧកញ៉ាប្រធានដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលមានសមាសភាពដូចជាលោកជំទាវអ្នកឧកញ៉ា សុខ សុភាព លោកជំទាវឧកញ៉ា ឆាយ ស៊ីវលីន លោកជំទាវឧកញ៉ា ស្រ៊ាត មុំសុភា និង ឧកញ៉ា សុខ បញ្ញារិទ្ធ ចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់ធុរកិច្ច (Business Lunch) រវាងថ្នាក់ដឹកនាំក្រុមហ៊ុន សហគ្រាស និងធុរជននៃប្រទេសកម្ពុជា នឹងតួកគី។

កម្មវិធីដ៏មានសារៈសំខាន់នេះត្រូវបានរៀបចំឡើងដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងអ៊ីស្តានប៊ុល នៃសាធារណរដ្ឋតួកគី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា ព្រមទាំងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលតួកគីដែលមានសមាសភាពដូចជា ឯកឧត្តម Mustafa Tuzcu អនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, លោក Mahir Alp ប្រធានក្រុមប្រឹក្សាធុរកិច្ចទួកគី-កម្ពុជា និងថ្នាក់ដឹកនាំក៏ដូចជាតំណាងវិស័យឯកជននៃប្រទេសទាំងពីរជាច្រើនរូបទៀត។

សូមបញ្ជាក់ថាកម្មវិធីអាហារថ្ងៃត្រង់ធុរកិច្ចនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជំរុញឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ក៏ដូចជាវិនិយោគរវាងប្រទេសទាំងពីរ តាមរយៈកិច្ចពិភាក្សានិងការផ្គូរផ្គងធុរកិច្ចរបស់ធុរជននានាដែលមានសក្តានុពលលើវិស័យទេសចរណ៍ កសិ-ឧស្សាហកម្ម និងសុខាភិបាលជាដើម។














## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ អមដំណើរដោយថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ ៣ឆ្នាំដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសិកា នង តាំងអ៊ីម

នាព្រឹកថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវព្រមទាំងលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទានគម្រប់ ៣ឆ្នាំដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសិកា នង តាំងអ៊ីម ដែលត្រូវជាម្តាយបង្កើតរបស់ឯកឧត្តមគង់វិបុលរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

ក្នុងឱកាសនោះដែរ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ាទាំងអស់បានចូលរួមអនុមោទនាទទួលយកមហាកុសលផលបុណ្យតាមកម្លាំងសទ្ធាជ្រះថ្លា និងបំណងប្រាថ្នារៀងៗខ្លួន។











## អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជាទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោក Makoto Matsukawa ប្រធានក្រុមហ៊ុន MK Co., Ltd.

នារសៀលថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា បានទទួលស្វាគមន៍ និងពិភាក្សាការងារជាមួយលោក Makoto Matsukawa ប្រធានក្រុមហ៊ុន MK Co., Ltd. និងក្រុមការងារ នៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា ស្ថិតនៅសណ្ឋាគារភ្នំពេញ ។

ជំនួបនេះ ត្រូវបានរៀបចំឡើងដើម្បីជួបសម្តែងការគួរសម និងស្វែងយល់អំពីសមាគមឧកញ៉ាកម្ពុជា ក៏ដូចជាបរិយាកាសធុរកិច្ចនិងវិនិយោគនៅកម្ពុជាក្នុងឱកាសដែលក្រុមហ៊ុនកំពុងបំពេញទស្សនកិច្ចធុរកិច្ចនៅកម្ពុជា។សូមជម្រាបជូនថា ក្រុមហ៊ុន MK Co., Ltd. គឺជាក្រុមហ៊ុនដឹកញ្ជូន និងភ័ស្តុភារ ដែលមានទីស្នាក់ការនៅទីក្រុងហ៊ីរ៉ូស៊ីម៉ា ប្រទេសជប៉ុនហើយការបំពេញទស្សនកិច្ចនេះគឺដើម្បីសិក្សាទីផ្សារនិងស្វែងរកដៃគូសហការវិនិយោគក្នុងគោលបំណងពង្រីកអាជីវកម្មនៅកម្ពុជានាពេលខាងមុខ។

ជាកិច្ចឆ្លើយតប អ្នកឧកញ៉ា ហ៊ុន ឡាក់ បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោក Makoto Matsukawa និងក្រុមការងារនិងបានជម្រាបជូនអំពីសាវតា តួនាទីភារកិច្ចស្នូលនិងសកម្មភាពសំខាន់ៗរបស់សមាគមដែលជាស្ថាប័នតែមួយគត់នៅកម្ពុជាតំណាងឱ្យនិងជាបណ្តុំនៃធុរជននិងវិនិយោគិនមកពីចម្រុះវិស័យ។អ្នកឧកញ៉ាក៏បានចែករំលែកអំពីកត្តាទាក់ទាញចម្បងៗក្នុងការវិនិយោគនៅកម្ពុជាព្រមទាំងលើកទឹកចិត្តនិងផ្តល់គាំទ្រដល់ក្រុមហ៊ុនMKCo.,Ltd. សម្រាប់ការឈានជើងចូលមកកាន់ប្រទេសកម្ពុជាផងដែរ។

លោក Makoto Matsukawa បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកឧកញ៉ា ដែលបានផ្តល់ជាអនុសាសន៍ និងព័ត៌មានសំខាន់ៗសម្រាប់ជាមូលដ្ឋានដល់លោក ហើយលោកនឹងផ្សព្វផ្សាយអំពីកម្ពុជាទៅកាន់សហគមន៍ធុរកិច្ចជប៉ុនព្រមទាំងកៀរគរធុរជននិងវិនិយោគិនជប៉ុនមកបំពេញទស្សនកិច្ចធុរកិច្ចនៅកម្ពុជានាពេលណាមួយខាងមុខ។








# លោកអ្នកឧកញ៉ា លាង ឃុន ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុង ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស















នាព្រឹកថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លាង ឃុន អនុប្រធានសមាគមឧកញ៉ាកម្ពុជា តំណាងលោកអ្នកឧកញ៉ាប្រធាន បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

សូមបញ្ជាក់ថា **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** បានយាងចូលព្រះទិវង្គត នៅវេលាម៉ោង ៥៖៤០នាទីល្ងាច ថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ក្នុងព្រះជន្មាយុ ៩៣ព្រះវស្សាដោយព្រះជរាពាធ។

## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ រួមជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការកំពង់ផែពហុបំណងកំពត

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវព្រមទាំងលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ាជាច្រើនរូបទៀតដែលជាថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាលក៏ដូចជាសមាជិកសមាគមឧកញ៉ាកម្ពុជាបានចូលរួមក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការកំពង់ផែពហុបំណងកំពតក្រោមទុនវិនិយោគរបស់ក្រុមហ៊ុនកំពតផតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

កំពង់ផែពហុបំណងកំពតនេះត្រូវបានរំពឹងថានឹងក្លាយជាសរសៃឈាមដ៏សំខាន់សម្រាប់ការដឹកជញ្ជូនតាមផ្លូវសមុទ្ររបស់កម្ពុជាដែលនឹងចូលរួមចំណែកក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យមានកំណើនបន្ថែមទៀតហើយនឹងក្លាយជាកំពង់ផែទឹកជ្រៅមួយបន្ថែមទៀតរបស់កម្ពុជាដែលនឹងជួយបំពេញបន្ថែមឱ្យកំពង់ផែស្វយ័តក្រុងព្រះសីហនុនិងកំពង់ផែស្វយ័តភ្នំពេញហើយការដឹកជញ្ជូនតាមផ្លូវសមុទ្រពីកំពង់ផែពហុបំណងកំពតទៅកាន់ប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកអាចដំណើរការទៅបានដោយពុំចាំបាច់ប្តូរនាវានៅកំពង់ផែណាមួយឡើយលើកលែងតែការដឹកជញ្ជូនទំនិញទៅកាន់សហរដ្ឋអាម៉េរិក និងអឺរ៉ុបដែលតម្រូវឱ្យប្តូរនាវានៅកំពង់ផែធំៗមុននឹងទៅដល់គោលដៅចុងក្រោយ។

ពិធីសម្ពោធនៅថ្ងៃនេះគឺជាសក្ខីភាពបង្ហាញឱ្យឃើញពីសមិទ្ធផលថ្មីមួយបន្ថែមទៀតនិងការអភិវឌ្ឍរីកចម្រើនរបស់កម្ពុជានិយាយជារួមនិងការរីកចម្រើនលើវិស័យដឹកជញ្ជូនតាមផ្លូវទឹកនិងកំពង់ផែនិយាយដោយឡែកដែលបានលេចចេញជារូបរាងឡើងស្របតាមគោលនយោបាយដ៏ត្រឹមត្រូវនិងច្បាស់លាស់ប្រកបដោយភាពប្រាកដនិយមរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីពង្រឹង និងលើកកម្ពស់ការអភិវឌ្ឍវិស័យកំពង់ផែនៅកម្ពុជា។ បន្ថែមពីនេះ កំពង់ផែនេះ ក៏ជាការបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់និងការផ្តល់ឱកាសពីសំណាក់ប្រមុខរាជរដ្ឋាភិបាលដល់វិស័យឯកជនជាពិសេសក្នុងការចូលរួមវិនិយោគអភិវឌ្ឍវិស័យកំពង់ផែនៅកម្ពុជាឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។















KAMPOT PORT
CAMBODIA
មោទនភាពជាតិ








Port





## អ្នកឧកញ៉ា ហ៊ុន ឡាក់ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុង "បេសកកម្មគោះទ្វារផ្សព្វផ្សាយទាក់ទាញអ្នកវិនិយោគនៅសហភាពអឺរ៉ុប"




តបតាមការអញ្ជើញរបស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ សមាគមឧកញ៉ាកម្ពុជា ធ្វើជាតំណាងលោកអ្នកឧកញ៉ាប្រធានដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលមានសមាសភាពដូចជា អ្នកឧកញ៉ា គួន ធីតា និង ឧកញ៉ា លាង ពៅ ចូលរួមអមដំណើរឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រីអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងបេសកកម្មគោះទ្វារផ្សព្វផ្សាយទាក់ទាញអ្នកវិនិយោគនៅសហភាពអឺរ៉ុបកាលពីថ្ងៃទី៩-១៤ ខែមិថុនា ឆ្នាំ២០២៤ ។

ក្នុងដំណើរបេសកកម្មនេះ ប្រតិភូនៃសមាគមឧកញ៉ាកម្ពុជាបានចូលរួមអមដំណើរ ឯកឧត្តម ស៊ុន ចាន់ថុល ក្នុងជំនួបពិភាក្សាការងារជាមួយលោកជំទាវរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មអេស្ប៉ាញ, លោកស្រីនាយិកាប្រតិបត្តិសភាពាណិជ្ជកម្មអេស្ប៉ាញ, លោកស្រីអភិបាលរងក្រុង Nuremberg នៃប្រទេសអាល្លឺម៉ង់, លោកនាយកប្រតិបត្តិនៃសភាពាណិជ្ជកម្ម និងឧស្សាហកម្មអាល្លឺម៉ង់, ថ្នាក់ដឹកនាំសភាពាណិជ្ជកម្មក្រៅប្រទេសអាល្លឺម៉ង់ និងចូលរួមជំនួបផ្គូរផ្គងធុរកិច្ចជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រុមហ៊ុនដែលមានសក្តានុពលរបស់ប្រទេសទាំងពីរប្រមាណជាង៤០និងបានបំពេញទស្សនកិច្ចនៅតាមមជ្ឈមណ្ឌលរបស់ក្រុមហ៊ុនធំៗមួយចំនួនដូចជា ក្រុមហ៊ុន Acciona Energía, ក្រុមហ៊ុន INSUDPHARMA, ក្រុមហ៊ុន UVEX, មជ្ឈមណ្ឌលដឹកជញ្ជូន BayernhafenNürnberg, ក្រុមហ៊ុន NürnbergMesse និងក្រុមហ៊ុនខ្នាត យក្ស Bosch ជាដើម។

ក្នុងអំឡុងពេលបំពេញបេសកកម្ម ឯកឧត្តម ស៊ុន ចាន់ថុល បានធ្វើបទបង្ហាញព្រមទាំងជម្រាបជូនវិនិយោគិនថ្នាក់ដឹកនាំនៃសភាពាណិជ្ជកម្មអេស្ប៉ាញ និងអាល្លឺម៉ង់ក៏ដូចជាគ្រប់តួអង្គពាក់ព័ន្ធនូវសក្តានុពលក្នុងការវិនិយោគនៅកម្ពុជារួមទាំងអំពីលក្ខខណ្ឌអំណោយផលនៃច្បាប់វិនិយោគក៏ដូចជាការលើកទឹកចិត្តនានារបស់រាជរដ្ឋាភិបាលកម្ពុជា ថែមទាំងបានណែនាំពីវិនិយោគិនសំខាន់ៗក្នុងគោលបំណងធ្វើជាដៃគូផ្គូផ្គងធុរកិច្ចពីសមាគមឧកញ៉ាកម្ពុជានិងសភាពាណិជ្ជកម្មកម្ពុជាដែលសុទ្ធតែមានសក្តានុពលបាននិងកំពុងវិនិយោគហើយរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងរៀបចំហេដ្ឋារចនាសម្ព័ន្ធពហុមធ្យោបាយជាពិសេសបានដាក់ចេញនូវ

ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយ និងភស្តុភារកម្មកម្ពុជា ២០២៣-២០៣៣ ដែលអនុញ្ញាតឱ្យមានការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធជាច្រើនដើម្បីជំរុញសេដ្ឋកិច្ចជាតិផងដែរស្របគ្នានឹងអំណះអំណាងរបស់ធនាគារពិភពលោកថា«កម្ពុជាគឺជាប្រទេសដែលមានរបបវិនិយោគសេរីជាងគេបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍» ដោយសារកម្ពុជាពុំមានការធ្វើជាតូបនីយកម្ម, ការធ្វើអស្សាមិករណ៍ផ្ទុយនឹងច្បាប់កំណត់, ការត្រួតពិនិត្យលើការប្តូរប្រាក់និងការត្រួតពិនិត្យលើការផ្ទេរមូលធនមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលឆ្លុះបញ្ចាំងតាមអត្រាកំណើនខ្ពស់ អត្រាអតិផរណាទាប អត្រាប្តូរប្រាក់មានស្ថិរភាព រួមទាំងអត្រាការប្រាក់ថយចុះ, ការកើនឡើងនូវអាយុរំពឹងទុកប្រមាណ១៥ឆ្នាំក្នុងរយៈពេល២០ឆ្នាំចុងក្រោយដែលបានឆ្លុះបញ្ចាំងអំពីជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ,ការនាំចូលទៅកាន់តំបន់អឺរ៉ុបដោយមិនជាប់ពន្ធក្រោមយន្តការ EBA (Everything But Arms) ព្រមទាំងការផ្តល់ការលើកទឹកចិត្តដ៏ទូលំទូលាយផ្សេងៗទៀត។

ជាមួយគ្នានេះប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលសុទ្ធសឹងជាពាណិជ្ជករនិងជាវិនិយោគិនដែលកំពុងវិនិយោគផ្ទាល់នៅក្នុងប្រទេសកម្ពុជាបានជម្រាបជូនបណ្តាដៃគូបរទេសនូវបទពិសោធន៍ជាក់ស្តែងអំពីស្ថានភាពក៏ដូចជាកាលានុវត្តភាពធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាពិសេសបានណែនាំអំពីវិស័យដែលកំពុងមានសក្តានុពលផងដែរ។




ជាលទ្ធផលលោកជំទាវរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មអេស្ប៉ាញបានបង្ហាញនូវចំណាប់អារម្មណ៍ក្នុងការជំរុញការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន, ទេសចរណ៍, ឱសថ, ថាមពលកកើតឡើងវិញនិងប្រព្រឹត្តិកម្មទឹកកខ្វក់។ ស្របគ្នានេះ លោកស្រីអភិបាលរងក្រុង Nuremberg ក៏បានវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះហើយបានបង្ហាញនូវការគាំទ្រឱ្យមានក្រុមហ៊ុនអាល្លឺម៉ង់ទៅវិនិយោគនៅក្នុងប្រទេសកម្ពុជាឱ្យបានកាន់តែច្រើនបន្ថែមទៀតខណៈដែលក្រុមហ៊ុនធំៗរបស់ប្រទេសទាំងពីរបានបង្ហាញអំពីឆន្ទៈក្នុងការដាក់ទុនវិនិយោគការស្វែងរកដៃគូវិនិយោគក្នុងស្រុកនិងការចុះសិក្សាសក្តានុពលទីផ្សារកម្ពុជាជាក់ស្តែងក្នុងពេលដ៏ខ្លីខាងមុខ។

ជាការឆ្លើយតប ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ឯកឧត្តមរីករាយក្នុងការទទួលស្វាគមន៍ដោយនឹងបង្កើតនូវការិយាល័យច្រកចេញចូលតែមួយក្នុងគោលបំណងផ្សារភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាព្រមជាមួយវិស័យឯកជនដើម្បីរៀបចំទទួលវិនិយោគិនពីអេស្ប៉ាញ និងអាល្លឺម៉ង់នាពេលអនាគត។


uvex












#LikeABosch





## លោក យឿម ប៉ូរ៉ាន អគ្គលេខាធិការរង តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិង ផ្សព្វផ្សាយទេសចរណ៍កម្ពុជា

នាព្រឹកថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ នៅសាលប្រជុំ២១២ ទីស្ដីការក្រសួងទេសចរណ៍ លោក យឿម ប៉ូរ៉ាន អគ្គលេខាធិការរងតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចូលរួមប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា(ក.ផ.ផ) ដើម្បីត្រួតពិនិត្យវឌ្ឍនភាពការងារ និងពិភាក្សាអំពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ព្រមទាំងពិភាក្សាពីប្រភពធនធានរបស់ ក.ផ.ផ ផងដែរ។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសមាជិក ក.ផ.ផ ដែលជាតំណាងក្រសួង-ស្ថាប័នចំនួន១២ រួមមានក្រសួងទេសចរណ៍,មហាផ្ទៃ,ការបរទេស,វប្បធម៌,និងក្រសួងបរិស្ថានចំណែកឯតំណាងវិស័យឯកជនរួមមានសមាគមឧកញ៉ាកម្ពុជា,សភាពាណិជ្ជកម្មកម្ពុជា,សហព័ន្ធទេសចរណ៍កម្ពុជា,ព្រលានយន្តហោះអន្តរជាតិភ្នំពេញ,ព្រលានយន្តហោះអន្តរជាតិសៀមរាប, លេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអាកាសចរណ៍អាស៊ី។

កិច្ចប្រជុំនេះដឹកនាំដោយ ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដោយផ្ដោតជាសំខាន់លើការគាំទ្រក្នុងការបង្កើត និងដំណើរការ ក.ផ.ផ ដែលមានរបៀបវារៈសំខាន់ចំនួន៣គឺ៖

១. ពិភាក្សាលើសេចក្ដីព្រាងលក្ខន្តិកៈក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ)
២. ពិភាក្សាលើសេចក្ដីព្រាងបទបញ្ជាផ្ទៃក្នុង ក.ផ.ផ
៣. ប្រភពធនធានទ្រទ្រង់ដល់ដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក.ផ.ផ

ជាកិច្ចចាប់ផ្ដើម អង្គប្រជុំទាំងមូលបានស្ដាប់នូវបទបង្ហាញរបស់ក្រុមការងារបច្ចេកទេសអំពីវឌ្ឍនភាពទូទៅរបស់ ក.ផ.ផ និងការស្នើសុំផ្ដល់ធាតុចូលលើឯកសារទាំង៣ខាងលើ។ ដោយមានការអនុញ្ញាតពី ឯកឧត្តមប្រធានអង្គប្រជុំសមាជិកអង្គប្រជុំទាំងមូលបានពិភាក្សានិងផ្ដល់ធាតុចូលលើរបៀបវារៈខាងលើយ៉ាងផុសផុលដើម្បីធ្វើឱ្យឯកសារទាំងនោះក្លាយជាឯកសារគតិយុត្តមួយដ៏សំខាន់ក្នុងការអនុវត្តនាពេលខាងមុខ។

ដោយសាររបៀបវារៈទាំងអស់បានពិភាក្សានិងផ្ដល់ធាតុចូលរួច,កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១៣:៣០នាទីរសៀលកាលបរិច្ឆេទដដែលក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។








## អ្នកឧកញ៉ា ហ៊ុន ឡាក់ ទទួលជួបនិងពិភាក្សាការងារ ជាមួយលោក KATO Kazunori អគ្គលេខាធិការសមាគមជប៉ុន-កម្ពុជា

នាព្រឹកថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា បានទទួលជួបនិងពិភាក្សាការងារជាមួយលោក KATO Kazunori អគ្គលេខាធិការសមាគមជប៉ុន-កម្ពុជា (Japan-Cambodia Association JCA) នៅការិយាល័យកណ្តាលនៃក្រុមហ៊ុន លី ហួរ គ្រុប។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងតាមការស្នើឡើងរបស់លោក KATO Kazunori ដើម្បីស្វែងយល់បន្ថែមអំពីសមាគមឧកញ៉ាកម្ពុជា និងបង្កើតទំនាក់ទំនងល្អរវាងសមាគមទាំងពីរ ជាពិសេសការពិនិត្យលទ្ធភាពក្នុងកិច្ចសហការរៀបចំ "ជំនួបផ្គូផ្គងធុរកិច្ច" នាពេលខាងមុខ។ លោក KATO Kazunori បានជម្រាបជូនថា សមាគមជប៉ុន-កម្ពុជាគ្រោងនឹងដឹកនាំគណៈប្រតិភូធុរកិច្ចជប៉ុនមកបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងអំឡុងខែវិច្ឆិកា ខាងមុខនេះ ដើម្បីស្វែងយល់អំពីសក្តានុពល និងបរិយាកាសធុរកិច្ច ក៏ដូចជា ឱកាសវិនិយោគនៅកម្ពុជា ហើយក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ សមាគមជប៉ុន-កម្ពុជា មានបំណងសហការរៀបចំ "ជំនួបផ្គូផ្គងធុរកិច្ច" រវាងគណៈប្រតិភូធុរកិច្ចនៃសមាគមទាំងពីរដើម្បីផ្តល់ឱកាសដល់ធុរជន/វិនិយោគិនកម្ពុជានិងជប៉ុនកសាងទំនាក់ទំនងធុរកិច្ចនិងស្វែងរកឱកាសចាប់ដៃគូវិនិយោគក្នុងវិស័យសក្តានុពលសំខាន់ៗ។

ជាការឆ្លើយតប អ្នកឧកញ៉ា ហ៊ុន ឡាក់ បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងបានធ្វើបទបង្ហាញអំពីសមាគមឧកញ៉ាកម្ពុជា ក៏ដូចជា បរិយាកាសធុរកិច្ចនិងឱកាសវិនិយោគនៅកម្ពុជា ព្រមទាំងរីករាយក្នុងកិច្ចសហប្រតិបត្តិការនានាក្នុងពេលអនាគតផងដែរ។

សូមជម្រាបផងដែរថាកិច្ចពិភាក្សានាថ្ងៃនេះគឺផ្តើមចេញពីជំនួបផ្លាស់ប្តូរទំនាក់ទំនងរវាងសមាគមទាំងពីរនៅក្នុងអំឡុងបេសកម្មទាក់ទាញនិងជំរុញវិនិយោគនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដឹកនាំដោយឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីដើមខែឧសភា ឆ្នាំ២០២៤ កន្លងទៅថ្មីៗនេះ។











# អ្នកឧកញ៉ា ហ៊ុន ឡាក់ជួបពិភាក្សាការងារជាមួយលោកស្រី Marisa Haruta ប្រធានតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ប្រចាំកម្ពុជា

នាព្រឹកថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគមឧកញ៉ាកម្ពុជា បានជួបពិភាក្សាការងារជាមួយលោកស្រី Marisa Haruta ប្រធានតំណាងអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ប្រចាំកម្ពុជា នៅការិយាល័យសមាគមឧកញ៉ាកម្ពុជា ។











កិច្ចប្រជុំនេះបានជជែកពិភាក្សាគ្នាលើកិច្ចសហការ ក្នុងការរៀបចំសន្និសិទចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងធុរកិច្ចកាបូនក្រេឌីត បច្ចេកវិទ្យាបៃតង និងវិស័យកសិកម្ម ជាពិសេសកិច្ចសហការរៀបចំ "ជំនួបផ្គូផ្គងធុរកិច្ច" រវាងធុរជន/វិនិយោគិនកម្ពុជានិងជប៉ុននៃស្ថាប័នទាំងពីរដែលប្រកបជំនួញក្នុងវិស័យធុរកិច្ចបៃតង ដោយគ្រោងនឹងរៀបចំនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤ នាពេលខាងមុខនេះ។ យោងតាមកិច្ចពិភាក្សា ព្រឹត្តិការណ៍ខាងលើនេះនឹងប្រព្រឹត្តទៅក្រោមអធិបតីថ្នាក់ដឹកនាំរដ្ឋាភិបាល ព្រមទាំងមានការចូលរួមពីស្ថាប័នរដ្ឋ វិស័យឯកជនកម្ពុជានិងជប៉ុន និងភាគីពាក់ព័ន្ធ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីធុរកិច្ចឥណទានកាបូន បច្ចេកវិទ្យាបៃតង និងវិស័យកសិកម្ម និងលើកទឹកចិត្តដល់ធុរជន/វិនិយោគិនចូលរួមក្នុងការធ្វើធុរកិច្ចបៃតងឱ្យកាន់តែច្រើនថែមទៀត។ ក្រៅពីសន្និសីទខាងលើក៏នឹងមានការរៀបចំជាការបំពេញទស្សនកិច្ចតាមទីតាំងផ្ទាល់និងជំនួបផ្គូផ្គងធុរកិច្ចរវាងគណៈប្រតិភូធុរកិច្ចជប៉ុន និងសមាជិកសមាគមឧកញ៉ាកម្ពុជា ដើម្បីផ្តល់ឱកាសចាប់ដៃគូសហការវិនិយោគ និងផ្គូផ្គងធុរកិច្ចជាមួយគ្នា។

ជាការឆ្លើយតប អ្នកឧកញ៉ា ហ៊ុន ឡាក់ បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅក្នុងកិច្ចសហការរៀបចំព្រឹត្តិការណ៍ខាងលើព្រមទាំងនឹងកៀរគរសមាជិកសមាគមចូលរួមឱ្យបានច្រើនកុះករផងដែរ។អ្នកឧកញ៉ាមានសុទិដ្ឋិនិយមខ្ពស់ថាព្រឹត្តិការណ៍ធុរកិច្ចនេះនឹងមិនត្រឹមផ្តល់ឱកាសក្នុងការសហការវិនិយោគរវាងក្រុមហ៊ុនកម្ពុជា-ជប៉ុនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជំរុញទំនាក់ទំនង និងសកម្មភាពពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យកាន់តែសកម្មថែមទៀត។

## ពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា

បន្ទាប់ពីទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នាព្រឹកថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជារួមមានថ្នាក់ដឹកនាំក្រុមប្រឹក្សាភិបាលនិងសមាជិកចំនួន៧៣រូបដែលជាសប្បុរសជនបានបរិច្ចាគថវិកាក្នុងឱកាសខួបទី១៦១ទិវាពិភពលោកកាកបាទក្រហមនិងអឌ្ឍចន្ទក្រហមដើម្បីចូលរួមក្នុងកម្មវិធីចូលជួបសម្តែងការគួរសមប្រគល់ថវិកានិងពិធីសំណេះសំណាលក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។

លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានជម្រាបជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** អំពីសកម្មភាពការងារនិងសមិទ្ធផលដែលសមាគមឧកញ៉ាកម្ពុជាសម្រេចបាននាពេលកន្លងមកទាំងនៅក្នុងសកម្មភាពធុរកិច្ចក៏ដូចជាការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដោយបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរជាង៣០ម៉ឺនកន្លែងព្រមទាំងសកម្មភាពសប្បុរសធម៌ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នមនុស្សធម៌នានាផងដែរ។

ជាក់ស្តែងនៅថ្ងៃនេះ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាបាននាំយកនូវថវិកាចំនួន១.៥៥៥.៥៥៥ដុល្លារអាម៉េរិកប្រគល់ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាថវិកាបានពីការចូលរួមបរិច្ចាគរបស់សមាជិកចំនួន១០០រូបក្នុងឱកាសខួបទី១៦១ទិវាពិភពលោកកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ឆ្នាំ២០២៤។









នៅក្នុងឱកាសដ៏វិសេសវិសាលនេះ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** បានផ្ដល់កិត្តិយសថ្លែងនូវសុន្ទរកថាពោរពេញដោយអត្ថន័យសម្រាប់អង្គពិធីដោយសម្ដេចបានរំលឹកអំពីប្រវត្តិនៃការបង្កើតនិងវឌ្ឍនភាពរបស់កាកបាទក្រហមកម្ពុជាដែលបានឆ្លងកាត់នូវការលំបាក និងការតស៊ូយ៉ាងច្រើនទម្រាំឈានមកដល់សព្វថ្ងៃនេះ។ **សម្ដេច**បានគូសបញ្ជាក់ថាកាកបាទក្រហមកម្ពុជាគឺជាសេនាធិការដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជាលើសកម្មភាពមនុស្សធម៌និងសង្គមកិច្ចដែលបានចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយទុក្ខលំបាកនានារបស់ប្រជាពលរដ្ឋក្រីក្រនិងជនរងគ្រោះនានាដូចជាគ្រោះធម្មជាតិ បញ្ហាសុខភាព ចរាចរណ៍ កង្វះចំណីអាហារ លំនៅឋាន ជាដើមរហូតសហព័ន្ធអន្តរជាតិនៃកាកបាទក្រហម និងអឌ្ឍចន្ទក្រហមបានប្រគល់ជ័យលាភីឆ្នើមជាងគេជូនដល់កាកបាទក្រហមកម្ពុជា។

**សម្ដេចប្រធាន** បានបន្ថែមថា គិតចាប់ពីឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្នកាកបាទក្រហមកម្ពុជាទទួលបានជោគជ័យជាបន្តបន្ទាប់មកនេះគឺមិនអាចខ្វះបាននូវការចូលរួមពី លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា យ៉ាងសកម្មក្នុងសកម្មភាពមនុស្សធម៌ដោយបានបរិច្ចាគនូវធនធាននិងសម្ភារៈជាច្រើនដើម្បីទុកលទ្ធភាពដល់កាកបាទក្រហមកម្ពុជាបំពេញតួនាទីក្នុងការឆ្លើយតបទៅនឹងការខ្វះខាតជាក់ស្ដែងនិងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋរងគ្រោះ។

ទន្ទឹមនឹងនេះ **សម្ដេច** ក៏បានមានប្រសាសន៍គាំទ្រយ៉ាងពេញទំហឹងចំពោះការបង្កើតសមាគមឧកញ៉ាកម្ពុជាដែលមានចក្ខុវិស័យ បេសកកម្ម និងរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់ដោយមាន **សម្ដេចតេជោ ហ៊ុន សែន** ជាប្រធានកិត្តិយស និងកំពុងតែមានភាពរីកចម្រើនជាលំដាប់ព្រមទាំងមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចនានានិងថ្នាក់ដឹកនាំកំពូលៗជាច្រើនជាពិសេសតាមរយៈព្រះរាជក្រឹត្យស្ដីពីគោរមងារឧកញ៉ាហើយបាននិងកំពុងបំពេញតួនាទីដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដើម្បីរួមចំណែកជំរុញឱ្យព្រះរាជាណាចក្រកម្ពុជាកាន់តែរីកចម្រើនជឿនលឿន។

ក្នុងឱកាសដ៏មានអត្ថន័យសម្រាប់សមាគមឧកញ៉ាកម្ពុជា **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានផ្តល់នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ដល់ថ្នាក់ដឹកនាំ និងសមាជិកទាំងអស់នៃសមាគមឧកញ៉ាកម្ពុជាចំនួន ៣ចំណុចដូចខាងក្រោម៖

១. សូម លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ទាំងអស់ត្រូវរួបរួមគ្នាជាធ្លុងមួយក្រោមដំបូលសមាគមឧកញ៉ាកម្ពុជាតែមួយក្នុងទិសដៅស្របគ្នាដើម្បីឆ្ពោះទៅកាន់ភាពរីកចម្រើនខ្លួនឯង សមាគម និងសង្គមជាតិទាំងមូល

២.សមាគមឧកញ៉ាកម្ពុជាត្រូវពង្រឹងនិងពង្រីកសកម្មភាពរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិកដោយប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាព ឯកភាពគ្នាជាធ្លុងមួយ

៣. សូម លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ទាំងអស់ បន្តចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិ ជាពិសេសបន្តចូលរួមក្នុងសកម្មភាពសនុស្សធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃនេះ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ក៏បានប្រគល់ជូននូវ "**ពានមាសឧកញ៉ា**" របស់សមាគមឧកញ៉ាកម្ពុជា ជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាកិត្តិយសដ៏ឧត្តុងឧត្តម និងជាការគោរពដឹងគុណដ៏ជ្រាលជ្រៅចំពោះគំរូវីរភាព និងពលិកម្មដ៏មានតម្លៃមិនអាចកាត់ថ្លៃបានដែល **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ក្នុងការដឹកនាំចលនាកាកបាទក្រហមកម្ពុជាឱ្យទទួលបានជោគជ័យដ៏ត្រចះត្រចង់ជាពិសេសបានលើកកម្ពស់តម្លៃ និងតួនាទីស្ត្រីកម្ពុជាឱ្យមានយល់ដឹងនិងទទួលស្គាល់កាន់តែខ្លាំងក្លាពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

គួររំលឹកផងដែរថា កាលពីឆ្នាំ២០២៣កន្លងមក លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ក៏បានដឹកនាំសមាជិកសមាគមឧកញ៉ាកម្ពុជានាំយកថវិកាប្រគល់ជូនកាកបាទក្រហមកម្ពុជា ចំនួន ១.៣៤៣.០០០ ដុល្លារអាម៉េរិកក្នុងឱកាសខួបទី១៦០ ទិវាកាកបាទក្រហម និងអឌ្ឍចន្ទក្រហមផងដែរ។


















$1,555,555













## លោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធឧបាសិកា តាំង ប៉ជូរ

នារសៀលថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤លោកជំទាវលោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ អនុប្រធានសមាគមឧកញ៉ាកម្ពុជា និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធឧបាសិកា តាំង ប៉ជូរ ដែលត្រូវជាម្តាយបង្កើតរបស់អ្នកឧកញ៉ា គង់ សាង សមាជិកក្រុមប្រឹក្សាភិបាលសមាគមឧកញ៉ាកម្ពុជាដែលបានទទួលមរណភាពកាលពីវេលាម៉ោង ១១:៣០នាទីយប់ថ្ងៃអាទិត្យ ២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៤ ក្នុងជន្មាយុ ៩២ឆ្នាំដោយជរាពាធ។

ក្នុងវេលាប្រកបដោយទុក្ខព្រួយដ៏សោកសង្រេងជាទីបំផុតនេះ លោកជំទាវលោកអ្នកឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ បានពាំនាំនូវបណ្តាំផ្ញើប្រកបដោយសមានចិត្ត និងថវិកា ព្រមទាំងលិខិតរំលែកមរណទុក្ខពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាផងដែរ។

ជាមួយគ្នានេះ យើងខ្ញុំទាំងអស់គ្នាសូមចូលរួមរំលែកមរណទុក្ខដ៏ក្រៀមក្រំជាមួយអ្នកឧកញ៉ា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារដោយសេចក្តីអាឡោះអាល័យបំផុត និងសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ ឧបាសិកា តាំង ប៉ជូរ សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។










# បេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជា

១ តំណាង និងការពារផលប្រយោជន៍ក៏ដូចជាកិត្តិយសរបស់សមាជិក

២ កសាងទំនាក់ទំនងប្រកបដោយមិត្តភាព សាមគ្គីភាព
សហប្រតិបត្តិការ ក្នុងមហាគ្រួសារឧកញ៉ា

៣ ជួយគ្នាទៅវិញទៅមក ផ្លាស់ប្តូរព័ត៌មាន និងការពិគ្រោះយោបល់

៤ បង្កើនកិត្យានុភាព ឧត្តមភាព និងគុណធម៌របស់ឧកញ៉ាឱ្យកាន់តែរីកចម្រើន
និងរុងរឿងនាពេលអនាគតដោយផ្សារភ្ជាប់ការចូលរួមក្នុងសកម្មភាពសង្គម និងមនុស្សធម៌នានា

៥ លើកកម្ពស់ការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា
ក្នុងព្រះរាជាណាចក្រកម្ពុជា

៦ ជំរុញផ្សព្វផ្សាយសក្តានុពល និងកាលានុវត្តភាពនៃការវិនិយោគ
ក្នុងព្រះរាជាណាចក្រកម្ពុជា

៧ បង្កើតវេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗពាក់ព័ន្ធនឹងធុរកិច្ច ពាណិជ្ជកម្ម
ការវិនិយោគ និងវិស័យដទៃដើម្បីជាគុណប្រយោជន៍សម្រាប់សង្គមនិងសេដ្ឋកិច្ចជាតិ ។

# អត្ថប្រយោជន៍ក្នុងការក្លាយជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា

១ ក្លាយជាសមាជិកនៃមហាគ្រួសារឧកញ៉ាកម្ពុជាដែលប្រមូលផ្តុំដោយគោរមវន្តជាលោកអ្នកឧកញ៉ាអ្នកឧកញ៉ា និងឧកញ៉ាដែលសុទ្ធសឹងជាធុរជនកំពុងប្រកបអាជីវកម្មលើពហុវិស័យប្រកបដោយកិត្តិនាមល្អនៅក្នុងប្រទេសកម្ពុជាដែលជាប្រភពទាក់ទាញដៃគូវិនិយោគទាំងក្នុងនិងក្រៅប្រទេស

២ ទទួលបានឯកសណ្ឋានគោរមងារឧកញ៉ាចំនួន ១ឈុត និងអាំងស៊ីងឧកញ៉ាធ្វើអំពីមាស ១៨K ចំនួន ១ផងដែរ

៣ ទទួលបាននូវការចុះឈ្មោះចូលក្នុងគេហទំព័រនិងបញ្ជីផ្លូវការនៃគោរមងារឧកញ៉ារបស់ស.ឧ.ក.ដែលបញ្ជាក់ពីភាពច្បាស់លាស់របស់សមាជិកម្នាក់ៗក្នុងនាមជាឧកញ៉ា

៤ ទទួលបានឱកាសចូលរួមក្នុងកម្មវិធីនានាដូចជាវេទិកាធុរកិច្ចការផ្គូផ្គងដៃគូពាណិជ្ជកម្មនិងការកសាងបណ្តាញធុរកិច្ចជាមួយបណ្តាគោរមវន្តជាសមាជិករបស់ស.ឧ.ក.ព្រមទាំងជាមួយធុរជនក៏ដូចជាវិនិយោគិនជាតិនិងអន្តរជាតិ

៥ ទទួលបាននូវការធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងគោរមងារឧកញ៉ា

៦ ទទួលបានការលើកតម្កើងបន្ថែមទៀតនូវគុណតម្លៃព្រមទាំងឧត្តមភាព និងកិត្តិនាមនៃគោរមងារឧកញ៉ានៅក្នុងសង្គមតាមរយៈការផ្សព្វផ្សាយព័ត៌មានល្អៗចេញពី ស.ឧ.ក.

៧ ទទួលបានការគាំទ្រ និងការគាំពារ ទាំងផ្នែកច្បាប់ និងជំនួយស្មារតីក្នុងពេលមានបញ្ហា ឬវិវាទផ្សេងៗដោយឈរលើគោលការណ៍សាមគ្គីភាពដើម្បីដោះស្រាយបញ្ហាប្រឈម (ស្របច្បាប់) រួមគ្នា

មានសិទ្ធិពេញលេញក្នុងការចូលរួមកិច្ចប្រជុំនិងពិធីជួបជុំនានារបស់ស.ឧ.ក.ដែលត្រូវបានរៀបចំឡើងដោយសមាគមឧកញ៉ាកម្ពុជា ជាពិសេសជំនួប និងការអមដំណើរប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាថ្នាក់ដឹកនាំនានានៅក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគព្រមទាំងសកម្មភាពពាណិជ្ជកម្ម និងធុរកិច្ចជាដើម

## ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ:

Website Facebook Telegram Youtube TikTok X(Twitter)

ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org